# ការធ្វើផែនទីនៃចិត្តលោកិយនិយម

## ដំណើរស្វែងរកនៃសម័យទំនើបសម្រាប់សង្គមមួយដែលគ្មានព្រះ




IIIT Books-In-Brief Series

# ការធ្វើផែនទីនៃចិត្តលោកិយនិយម

.

ដំណើរស្វែងរកនៃសម័យទំនើប

សម្រាប់សង្គមមួយដែលគ្មានព្រះ

Haggag Ali

@វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ ឆ្នាំ២០២៤

វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ(IIIT)
P.O. BOx 669
Herndon, VA 20172, USA
www.iiit.org

IIIT London Office
P.O. Box 126
Richmond, Surrey
TW9 2UD, UK
www.iiituk.com

សៀវភៅនេះស្ថិតក្នុងការរក្សាកម្មសិទ្ធិ។ កម្មវត្ថុនៃការលើកលែង និងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងជាសមូហភាពដែលពាក់ព័ន្ធមិនអាចផលិតឡើងវិញនូវផ្នែកណាមួយនៃសៀវភៅនេះ អាចធ្វើទៅបាននោះឡើយ បើសិនជាមិនមានការសរសេរលាយលក្ខណ៍អក្សរនៃការអនុញ្ញាតពីអ្នកបោះពុម្ពផ្សាយ។

ទស្សនៈ និងគំនិតដែលបានបង្ហាញក្នុងសៀវភៅនេះគឺជាគំនិតរបស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈ របស់អ្នកបោះពុម្ពឡើយ។

979-8-89193-329-3

ក្រុមអ្នកត្រួតពិនិត្យ
Dr. Anas S. al-Shaikh-Ali
Shiraz Khan

*កំណត់រចនាបថអក្សរដោយ Sideek Ali*
*រចនាក្របសៀវភៅដោយ Shiraz Khan*
*បោះពុម្ពផ្សាយនៅប្រទេសម៉ាល់តា ដោយក្រុមហ៊ុនGutenberg Press Ltd*

**ប្រភេទសៀវភៅសង្ខេបរបស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ(IIIT)**

សៀវភៅ IIIT Books-In-Brief Series គឺជាការប្រមូលផ្តុំដ៏មានតម្លៃនៃសៀវភៅ ដែលបានបោះពុម្ពផ្សាយសំខាន់ៗ របស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តជាតិ(IIIT) ដែលបានសរសេរ រៀបចំឡើងជាទម្រង់សង្ខេបខ្លី ខ្លឹម ដើម្បីផ្តល់ឱ្យមិត្តអ្នកអាន នូវការយល់ដឹងអំពីស្នូលនៃខ្លឹមសារសំខាន់ៗ នៃស្នាដៃសៀវភៅច្បាប់ដើមតែម្តង។ រៀបចំឡើងក្នុងទម្រង់ខ្លី ងាយស្រួលអានសន្សំសំចៃពេលវេលា សេចក្តីសង្ខេបនៃបណ្តាសៀវភៅទាំងនេះបានផ្តល់នូវភាពខ្លឹមនៃការបង្រួមខ្លឹមសារឲ្យកាន់តែខ្លី និងសរសេរដោយប្រុងប្រយ័ត្នបំផុតពីសៀវភៅដើមដែលមានពិពណ៌នាច្រើនជាងនេះ ដែលយើងខ្ញុំសង្ឃឹមថាមិត្តអ្នកអាននឹងស្វែងយល់បន្ថែមពីបណ្តាសៀវភៅដើមពេញទំព័រដែលមិនទាន់បានសង្ខេបជាបន្ត។

ការសិក្សារបស់ Hagga Ali **អំពីការធ្វើផែនទីនៃចិត្តលោកិយនិយម ដំណើរស្វែងរកនៃសម័យទំនើបសម្រាប់សង្គមមួយដែលគ្មានព្រះ** ត្រូវបានបោះពុម្ពពេញលេញនៅក្នុងឆ្នាំ២០១៣។ គំនិតលោកិយមានផែនការធំមួយ គឺបង្កើតឋានសួគ៌នៅលើផែនដី ឋានសួគ៌នៅទីនេះ និងពេលវេលាឥលូវនេះ អរិយធម៌ទំនើបមួយដែលគ្រប់គ្រងដោយហេតុផលរបស់មនុស្ស សនិទានភាព និងជ័យជំនះនៃវឌ្ឍនភាព។ ខណៈពេលដែលឧត្តមគតិគឺជារឿងមួយ នោះគឺមធ្យោបាយនៃការយល់ដឹងថាវាគឺជាអ្វីផ្សេងទៀត។ ឆ្ងាយពីការឃោសនាបំផ្លើស ការរំដោះឲ្យមនុស្សចេញពី 'ខ្សែពួរ' ជំនឿលើព្រះ និងសាសនា វាមិនមែនជារឿងងាយស្រួលនោះឡើយ។

**ការធ្វើផែនទីពីនៃចិត្តលោកិយ** ពិនិត្យយ៉ាងត្រិះរិះពិចារណាលើបញ្ហានៃហេតុផល សនិទានភាព និងសម្ភារៈនិយមខាងលោកិយ ដើម្បីស្វែងយល់ពីរបៀបនៃការយល់ឃើញផ្លូវចិត្តទាំងនេះ ឬវិធីនៃការគូរផែនទីពិភពលោកបានជះឥទ្ធិពលដល់អន្តរកម្មរបស់មនុស្ស និងការអភិវឌ្ឍសង្គម។ របៀបបែបនេះនោះគឺដោយការប្រៀបធៀប និងគំនិតផ្ទុយរបស់ Abdelwahab M.Elmessiri (1938–2008) ដែលជាបញ្ញវន្តជនជាតិអារ៉ាប់ឈានមុខគេ និងលោកZygmunt Bauman(1925) ជាអ្នកសង្គមវិទូឈានមុខគេរបស់ពិភពលោក។ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការរិះគន់លោកខាងលិចដែលកំពុងលេចចេញអំពីភាពទំនើបបានបំផុសគំនិតបញ្ញវន្តមូស្លីមឱ្យបង្កើតគំនិតថ្មី រូបភាព លក្ខខណ្ឌ និងគោលគំនិតដែលបង្ហាញពីជំហររបស់ពួកគេចំពោះទំនោរនៃភាពទំនើបនិយម ការផ្លាស់ប្តូរ និងផលវិបាករបស់វា និងរបៀបដែលវាគ្រប់គ្រងការយល់ឃើញទៅលើការពិត។

សៀវភៅនេះប្រឈមនឹងមូលដ្ឋានគ្រឹះនៃមនោគមវិជ្ជាខាងលោកិយ ដើម្បីជជែកវែកញែកថា សេចក្តីប្រាថ្នារបស់វាបានផ្លាស់ប្តូរយ៉ាងខ្លាំងនូវមនសិកា និងអារម្មណ៍ផ្ទាល់ខ្លួនរបស់មនុស្ស ដោយទុកឱ្យវាក្លាយជាសភាវនៃការប្រើប្រាស់ដោយគ្មានគោលបំណង នឿយហត់ដោយការស្វែងរកការបំពេញ និងគ្រប់គ្រងដោយច្បាប់សម្ភារៈនិយមដែលគ្រប់គ្រងបុគ្គលនៃមនុស្សលោក។ វាក៏បានផ្តល់នូវនិក្ខេបបទ ឬការសិក្សាបង្ហាញមួយដែលងងឹតជាងនេះផងដែរ ដែលថារបបហ្វាហ្ស៊ីសអាល្លឺម៉ង់ និងចលនា Eugenics គឺជាទម្រង់នៃសង្គមដារវីននិយម ដែលត្រូវបានយកទៅតាមគំនិតបែបឡូជីខលរបស់វា។ Ali បានជជែកតវ៉ាថា ទាំងនេះមិនមែនជាការខុសអំពីគោលការណ៍នៃភាពទំនើបនោះទេ ប៉ុន្តែជាលទ្

ផលស្របគ្នានៃទស្សនៈពិភពលោកសម័យទំនើប ជាមួយនឹងគ្រាប់ពូជនៃការបំផ្លិចបំផ្លាញខ្លួនឯង ដែលត្បាញចូលតែមួយជាក្រណាត់នៃទស្សនវិជ្ជា ពោលគឺវាតែមួយនោះឯង។

---

**ការបោះពុម្ពស្នាដៃសៀវភៅសង្ខេបពីប្រភពដើមនៃស្នាដៃរបស់ Haggag Ali**
នៃសៀវភៅការធ្វើផែនទីពីនៃចិត្តលោកិយនិយម ដំណើរស្វែងរកនៃសម័យទំនើប
សម្រាប់សង្គមមួយដែលគ្មានព្រះ
Haggag Ali
ISBN : 979-8-89193-329-3
2024

# ជំពូកទី១
# ការណែនាំ

នៅក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការរិះគន់លោកខាងលិចអំពីទំនើបកម្ម វាបានបំផុសគំនិតដល់បញ្ញវន្តមូស្លីម ដើម្បីបង្កើតគំនិតថ្មី រូបភាព លក្ខខណ្ឌ និងគោលគំនិតថ្មីដែលបង្ហាញពីជំហររបស់ពួកគេឆ្ពោះទៅរកទំនោរនៃភាពទំនើបខាងលោកិយ ការផ្លាស់ប្តូរ និងផលវិបាករបស់វា។ ភាពទំនើបជាធម្មតាត្រូវបានសមមាត្រស្មើជាមួយនឹងឧត្តមគតិដ៏ខ្ពង់ខ្ពស់នៃការយល់ដឹងដ៏ឧត្តុងឧត្តម ជាពិសេសការសន្យាពីធម្មជាតិ ហេតុផល និងវឌ្ឍនភាពដើម្បីបង្កើតប្រព័ន្ធសមហេតុផល និងវឌ្ឍនភាពរបស់វា។ ទស្សនៈនេះបានផ្លាស់ប្តូរជាវិសាលភាពយ៉ាងធំបន្ទាប់ពីសង្គ្រាមលោកលើក២ និងការអភិវឌ្ឍមួយដ៏ស្មុគស្មាញរបស់បស្ចិមប្រទេស ដែលត្រូវបានលើកកម្ពស់ដោយស្នាដៃរបស់សាលាហ្វ្រែនហ្វើត។ ក្នុងការជជែកវែកញែករបស់គាត់ដើម្បីបង្ហាញការយល់ឃើញដ៏លេចធ្លោនៃភាពទំនើបនេះ បញ្ញវន្តមូស្លីមអារ៉ាប់អេហ្ស៊ីប Abdelwahab Elmessiri (1938-2008) ទទួលបានអត្ថប្រយោជន៍ពីកេរដំណែលលើការរិះគន់លោកខាងលិចនេះ។ ការរិះគន់របស់ Elmessiri អំពីភាពទំនើបអាចត្រូវបានគេមើលឃើញថាជាគោលបំណងធ្វើឲ្យសង្គមអ៊ីស្លាមមានភាពទំនើបនិយម ប៉ុន្តែជាការហួសចិត្តទៅវិញតាមរយៈការរិះគន់របស់លោកខាងលិច។

អស់រយៈពេលជិត៤ទសវត្សរ៍មកហើយ Elmessiri បានចូលរួមក្នុងការសិក្សាអំពីទស្សនវិជ្ជានៃសម័យទំនើបរបស់លោកខាងលិច និងទំនាក់ទំនងរបស់វាជាមួយនឹងមនោគមណាហ្ស៊ីនិយម និងស៊ីយូនីសជ្វីហ្វនិយម។ Elmessiri ជាធម្មតាស្នាដៃអត្ថបទរបស់គាត់សំដៅទៅលើអំឡុងពេលនៃការស្នាក់នៅរបស់គាត់នៅសហរដ្ឋអាមេរិក ក្នុងរយៈពេលដាច់ដោយឡែកពីគ្នា (1963-69/1975-79) ដែលវាមានសារៈសំខាន់ខ្លាំងណាស់ នូវគ្រាដែលបង្ហាញពីការយល់ដឹងរបស់គាត់អំពីការផ្លាស់ប្តូរពីសម័យទំនើបរបស់លោកខាងលិចជា "លំដាប់គំរូ" ដែលចាប់ផ្តើមអភិវឌ្ឍន៍ជាមួយនឹងសម្ភារៈនិយមរូបធាតុរឹង និងបញ្ចប់ដោយការអភិវឌ្ឍជាសម្ភារៈរូបធាតុ។[1] ទោះបីជាយ៉ាងណាក៏ដោយ ទសវត្សរ៍ឆ្នាំ 1970 គឺវាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការយល់ដឹងអំពី Elmesisri លើការរិះគន់នៃភាពទំនើបរបស់លោកខាងលិចរបស់លោក ដោយសារតែសម័យកាលនេះគេបានមើលឃើញពីការកើនឡើងនៃនយោបាយអ៊ីស្លាមបានគ្រប់គ្រងបន្ទាប់ពីការបរាជ័យរបស់អារ៉ាប់ដោយសង្គ្រាមជាមួយអ៊ីស្រាអែលនៅក្នុងឆ្នាំ1967 និងត្រូវបំពេញចន្លោះទំនេរនៃសម័យកាលនោះ ដែលបន្សល់ទុកដោយចលនាឆ្វេងនិយម។ លទ្ធផលនៃវឌ្ឍនភាពបច្ចេកវិទ្យារបស់ពួកគេ ពោលរបស់លោកខាងលិច ក៏ដូចជាសុន្ទរកថាឧត្តមគតិនៃសង្គមនិយមអារ៉ាប់ វាត្រូវបានគេប្រើដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃការបាត់បង់សេរីភាពនយោបាយជាថ្នូរនឹងលទ្ធភាពនៃការអភិវឌ្ឍជាតិ និងវឌ្ឍនភាពបច្ចេកវិទ្យា។ ទសវត្សរ៍ឆ្នាំ 1970 អាចត្រូវបានគេមើលឃើញថាជារយៈពេលដ៏មានភាពលេចធ្លោនៃនយោបាយនៃសង្គមអ៊ីស្លាម ដែលត្រូវបានទទួលយកដោយពួកឆ្វេងនិយមអេហ្ស៊ីបដ៏លេចធ្លោជាច្រើន យកធ្វើជាយាននៃការប្រកួតប្រជែងដ៏ពេញនិយមនិងការរំដោះជាតិរបស់ពួកគេ។[2]

នៅក្នុងស្នាដៃសុន្ទរកថាទស្សនទានទាំងលោកខាងលិច និងអារ៉ាប់ ភាពទំនើបគឺស្ទើរតែតែងតែទាក់ទងទៅនឹងឧត្តមគតិនៃការរីកចម្រើនចំណេះដឹង ជាពិសេសការសន្យាលើហេតុផល និងវិទ្យាសាស្ត្រដើម្បីលើកកម្ពស់អត្ថិភាពរបស់មនុស្ស និងសង្គម។ Elmessiri សំដៅលើការយល់ដឹងអំពីភាពទំនើបនេះគឺជា"លទ្ធិលោកិយនិយមដោយផ្នែក" ដែលគាត់បានពិពណ៌នាថាជា "លទ្ធិលោកិយនិយមខាងសីលធម៌" ឬ "លទ្ធិមនុស្សលោកនិយម" ។[3] យោងទៅតាម Elmessiri ការទទួលយកលទ្ធិនិយមនៅកម្រិតមធ្យមនេះជាផ្នែកសំខាន់នៃពហុនិយមត្រូវបានទទួលយកដោយនិន្នាការអ៊ីស្លាមដ៏សំខាន់ៗពោលនាពេលនោះ ដែលវាត្រូវបានតស៊ូមតិដោយ Fahmi Huwaidi, Yusuf al-Qaradawi, Mohammed Selim al-Awa, Abu al-Ela Madi, និង Adel Husain (អេហ្ស៊ីប), Rachid Ghannouchi (ទុយនីស៊ី),Taha Jabir Alalwani (អ៊ីរ៉ាក់),AbdulHamid AbuSulayman (អារ៉ាប៊ីសាអូឌីត) , Azzam Tamimi (ប៉ាឡេស្ទីន), Parviz Manzur (ប៉ាគីស្ថាន) និង Ahmet Davutoπlu (តួកគី)។ និន្នាការអ៊ីស្លាមនេះទទួលយកភាពស្របច្បាប់នៃលទ្ធិលោកិយនិយមកម្រិតមធ្យម និងតួនាទីរបស់អ្នកតស៊ូមតិរបស់ខ្លួនជាដៃគូក្នុងជីវិតនយោបាយនៃសង្គមអ៊ីស្លាម។ [4]

នៅក្នុង *Dira'sat Ma'rifiyyah fĪ al-Hadiyah al-Gharbiyyah* (ការសិក្សាក្នុងដែនវិសាលភាពនៅក្នុងសម័យទំនើបរបស់លោកខាងលិច) Elmessiri បំបែកការយល់ដឹងអំពីចរន្តនៃសម័យទំនើបលោកខាងលិច និងកំណត់វាថាជា "ការប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាគ្មានតម្លៃ"។ វាគឺជាទម្រង់នៃលទ្ធិលោកិយ៍និយមដ៏ទូលំទូលាយមួយ ដែលមិនមែនសំដៅលើឯករាជ្យភាពនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាពីវត្ថុបំណងរបស់មនុស្ស ឬការបំបែកចេញវិហារសាសនា និងរដ្ឋឲ្យនៅដាច់ចេញពីគ្នានោះទេ ប៉ុន្តែវាជា ការបំបែកចេញនូវតម្លៃទាំងអស់ (ទាំងសាសនា សីលធម៌ មនុស្ស) មិនមែនត្រឹមតែជា រដ្ឋ ប៉ុន្តែក៏ជាជីវិតសាធារណៈ និងឯកជន និងពីពិភពលោកទាំងមូល។ ម្យ៉ាងទៀតវាខិតខំបង្កើតពិភពលោកដែលគ្មានតម្លៃ"។ [6]

ក្នុងការណែនាំអំពីការបោះពុម្ពផ្សាយលើកទី3របស់ Al-subuniyyah wa al-Naziyyah wa Nihayat al-Tarikh (ណាហ្ស៊ីនិយម ស៊ីយូនីសជ្វីហ្វនិយម និងការបិទបញ្ចប់របស់ប្រវត្តិសាស្ត្រ) ឧទ្ទិសដល់អតីតបញ្ញវន្តបារាំងម៉ាក្សនិយម Roger Garaudy, Elmessiri បង្ហាញពីការភ្ញាក់ផ្អើលរបស់គាត់ចំពោះការពិតដែលថាមុនចុងទសវត្សរ៍ឆ្នាំ1980 ការផ្តល់អាហារូបករណ៍លោកខាងលិចស្ទើរតែមិនមានឡើយលើការសិក្សាដែលមាន ឬកៀកទៅនឹងមនោគមន៍ណាហ្ស៊ីនិយម និងស៊ីយូនីសជ្វីហ្វនិយម នៅក្នុងក្របខ័ណ្ឌនៃតម្លៃ សេរីនិយម ហេតុផលនិយម និងទំនើបភាវូបនីយកម្ម។

ទោះបីយ៉ាងណាក៏ដោយ Elmessiri សរសើរចំពោះការបកស្រាយរបស់ Zygmunt Bauman អំពីភាពទំនើបដោយនិយាយថាការសរសេររបស់គាត់ ជាពិសេស Modernity and the Holocaust (1989) គឺស្ថិតក្នុងចំណោមភាគច្រើនបំផុតនៃឯកសារយោងសំខាន់ៗដែលគាត់បានទាញមកដើម្បីអភិវឌ្ឍន៍ការយល់ដឹងរបស់គាត់នូវការគូរផែនទីនៃសម័យទំនើប។[7] នៅកន្លែងផ្សេងទៀតដែលគាត់បានសង្កត់ធ្ងន់ថាការសរសេររបស់Bauman គឺស្ថិតក្នុងចំណោមស្នាដៃដែលគាត់បានអានយ៉ាងប៉ិនប្រសប់ ពេលពួកគេលាតត្រដាងផ្នែកងងឹតដែលស្ថិតនៅក្រោមផ្ទៃភ្លឺចាំងដ៏រីករាយនៃសម័យទំនើប។[8]

ទោះបីជាមានសាសនា ជាតិ និងវប្បធម៌ខុសគ្នាក៏ដោយ។ Elmessiri (ជាតិអារ៉ាប់-អេហ្ស៊ីប-អតីតម៉ាក្សនិយម-មូស្លីម) និង Bauman(ជាតិប៉ូឡូញ-អង់គ្លេស-អតីតម៉ាក្សនិយម-ជ្វីហ្វ) បានប្រើពាក្យអត្តប្បដិរូបរបស់ជនជាតិជ្វីហ្វ ដើម្បីចូលទៅជិតនឹងចំណោទបញ្ហាដ៏ធំក្នុងសម័យទំនើបខាងលោកិយរួមមាន ណាហ្ស៊ីនិយម ការរើសអើងជាតិសាសន៍ ចក្រពត្តិនិយម និងបទពិសោធន៍របស់ជនជាតិជ្វីហ្វនៅក្នុងយុគសម័យសម័យទំនើប។ ការពិតដែលថា Bauman មានដើមកំណើតមកពីប្រទេសប៉ូឡូញផ្តល់ឱ្យការប្រៀបធៀបនេះនូវទំហំពិសេសមួយ ចាប់តាំងពីពេលដែលយើងនិយាយអំពីជនជាតិជ្វីហ្វនៅលោកខាងលិច យើងកំពុងនិយាយពីការពិត នេះបើយោងតាម Elmessiri អំពីជនជាតិប៉ូឡូញ! វាមាននៅក្នុងទសវត្សរ៍ឆ្នាំ1980 ដែល Elmessiri បានដឹងថាភាគច្រើនពីជនជាតិជ្វីហ្វនៅភាគលោកលិចនៅចុងសតវត្សរ៍ទី១៨ស្ថិតនៅក្នុងប្រទេសប៉ូឡូញ ហើយថាពួកគេត្រូវបានបែងចែកឲ្យភៀសខ្លួនទៅរស់ប្រទេសផ្សេងៗជាច្រើនក្នុងនោះរួមមានប្រទេសរុស្ស៊ី អូទ្រីស និងអាល្លឺម៉ង់ដោយការបែងចែកនៅក្នុងប្រទេសប៉ូឡូញផ្ទាល់ខ្លួន។ ចំនួនខ្ទង់រាប់ពាន់ និងខ្ទង់លាននាក់នៃពួកគេបានធ្វើចំណាកស្រុកទៅប្រទេសអង់គ្លេស អូទ្រីស កាណាដា សហរដ្ឋអាមេរិក អាហ្វ្រិកខាងត្បូង និងប៉ាឡេស្ទីន។[9] វាគឺស្ថិតនៅក្នុងប្រទេសប៉ូឡូញផងដែរ ដែលរឿងរ៉ាវផ្សេងទៀតនៃភាពទំនើបខាងលោកិយបានលេចឡើងយ៉ាងពេញលេញ។ នៅក្នុងប្រទេសប៉ូឡូញតែមួយ មានជំរុំប្រមូលផ្តុំរបស់ណាហ្ស៊ីចំនួន៦ត្រូវបានបង្កើតឡើង ដែលក្នុងនោះធំបំផុត និងពេញនិយមបំផុតគឺជំរុំ Auschwitz ។ ស្ថិតិដែលអាចជឿទុកចិត្តបាន យោងតាមលោក Gilbert Achcar បង្ហាញថានៅឆ្នាំ 1948 ជនជាតិជ្វីហ្វជិត 170,000នាក់មកពីប្រទេសប៉ូឡូញបានបង្កើតផ្នែកដ៏ធំបំផុតនៃសហគមន៍ជនជាតិជ្វីហ្វ ដែលភៀសខ្លួននៅរស់នៅក្នុងទឹកដីប៉ាឡេស្ទីន។[10] Bauman ខ្លួនឯងត្រូវបានបង្ខំឱ្យធ្វើអន្តោប្រវេសន៍ទៅកាន់ទឹកដីប៉ាឡេស្ទីននៅចុងទសវត្សរ៍ឆ្នាំ1960 ប៉ុន្តែគាត់បានជ្រើសរើសទៅប្រទេសអង់គ្លេសភ្លាមៗបន្ទាប់ពីទទួលបានការផ្តល់ជូនការងារពីសាកលវិទ្យាល័យ Leeds ។ Baumanកើតនៅប្រទេសប៉ូឡូញក្នុងឆ្នាំ 1925 ហើយគ្រួសាររបស់គាត់បានរត់គេចខ្លួនទៅរស់នៅតំបន់កាន់កាប់របស់សូវៀត បន្ទាប់ពីការលុកលុយរបស់ណាហ្ស៊ីនៅប៉ូឡូញ ជាពេលវេលានៃការចាប់ផ្តើមសង្គ្រាមលោកលើកទី២។នៅចុងទសវត្សរ៍ឆ្នាំ1950 លោកBauman ដូចជា Elmessiri បានដើរតួនាទីយ៉ាងសំខាន់ក្នុងលទ្ធិម៉ាក្សនិយមរបស់មនុស្សជាតិ ហើយគាត់នៅតែស្មោះត្រង់ចំពោះគោលការណ៍សំខាន់ៗនៃលទ្ធិម៉ាក្ស និងការបដិសេធចំពោះមនសិការមិនពិត។ នៅក្នុងទស្សវត្សរ៍ឆ្នាំ 1960 លោក Baumanបានក្លាយជាសមាជិកនៃគណបក្សរួបរួមពលករប៉ូឡូញ United Workers's Party ប៉ុន្តែគាត់មិនដែលយល់ព្រមលើការអនុវត្តនៃរបបកុម្មុយនិស្តនោះទេ។ នៅចុងទសវត្សរ៍ឆ្នាំ1960 ដើម្បីឱ្យច្បាស់លាស់នៅឆ្នាំ1968 លោក Bauman បានបោះបង់សមាជិកភាពបក្សរបស់គាត់ និងនៅក្នុងឆ្នាំដដែលនោះ ក្នុងយុទ្ធនាការប្រឆាំងជនជាតិជ្វីហ្វ គាត់រួមជាមួយបញ្ញវន្តជនជាតិជ្វីហ្វជាច្រើននាក់ ត្រូវបានគេបណ្តេញចេញពីប្រទេសប៉ូឡូញ និងបានដកហូតសញ្ជាតិប៉ូឡូញរបស់គាត់ ក្រោមការចោទប្រកាន់ពីបទបង្កកុប្បកម្មនិស្សិត។ Baumanត្រូវទៅអ៊ីស្រាអែលមុនគេជាកន្លែង ដែលគាត់ស្នាក់នៅមិនលើសពីបីឆ្នាំនោះឡើយ Janina Bauman ជាភរិយារបស់គាត់បានលាតត្រដាងនៅក្នុងការសន្ទនាជាមួយ Madeleine Bunting ថាមូលហេតុពិតនៅពីក្រោយការសម្រេចចិត្តរបស់ពួកគេក្នុងការចាកចេញពីអ៊ីស្រាអែលៈ "ខ្ញុំមិនមែនជាអ្នកប្រទេសជាតិនិយមទេ ហើយយើងទើបតែចាកចេញពីភាពជាតិនិយម។ យើងមិន

ចង់ទៅ ដើម្បីប្រែពីការធ្វើជាជនរងគ្រោះនៃជាតិនិយមមួយទៅជាអ្នកប្រព្រឹត្តអំពើអាក្រក់លើអ្នកដទៃនោះឡើយ ពោលដោយជាតិនិយមនោះទេ។"[11] នៅក្នុងការសន្ទនាជាមួយ Benedetto Vecchi លោកBaumanខ្លួនឯងមិនស្ទាក់ស្ទើរក្នុងការនិយាយថា "ខ្ញុំគិតថាភាពជាជនជាតិជ្វីហ្វរបស់ខ្ញុំត្រូវបានបញ្ជាក់ដោយភាពមិនស្មើគ្នារបស់អ៊ីស្រាអែលដែលធ្វើឲ្យខ្ញុំកាន់តែឈឺចាប់ជាងអំពើឃោរឃៅ ដែលប្រព្រឹត្តដោយប្រទេសដទៃទៅទៀត។" [12]

កត្តាជាតិនិយមដែលបង្ហាញពីភាពទំនើបរបស់បស្ចិមប្រទេសមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើការធ្វើផែនទីរបស់ Bauman នៃភាពទំនើប និងនៅសម័យទំនើប។ លក្ខណៈពិសេសនៃការរិះគន់របស់លោកបានលេចចេញជារូបរាងជាមួយនឹងការបោះពុម្ពផ្សាយការប្រៀបធៀបចំនួន៣របស់គាត់៖ អ្នកតាក់តែងច្បាប់ និងអ្នកបកប្រែ (1987), ទំនើបកម្ម និងវិនាសកម្ម (1989) ហើយនិងសម័យទំនើប និងភាពមិនប្រែប្រួល (1991)។ Bauman មិនដែលបោះបង់ជំនឿរបស់គាត់លើទំនាក់ទំនងដ៏រឹងមាំនោះទេ រវាងភាពទំនើប និងទំនើបនិយម ដោយលើកហេតុផលថា អ្នកសម័យទំនើបបានផ្តល់កក្តីភាពរបស់ពួកគេចំពោះការរកឃើញនៃវិទ្យាសាស្ត្រទំនើប ហើយបានបង្កើតទ្រឹស្តីរបស់ពួកគេនៅលើវិស័យវិទ្យាសាស្ត្រ។ គាត់សង្កត់ធ្ងន់ថា អ្នកដែលចាប់អារម្មណ៍បានយកការបំផុសគំនិតពីទ្រឹស្តីអុបទិក ទ្រឹស្តីគូបពីទ្រឹស្តីទំនាក់ទំនង និងការប្រាកដនិយមពីការវិភាគចិត្តសាស្ត្រ។[13] នៅកន្លែងផ្សេងទៀត Bauman អះអាងថា លទ្ធិទំនើបនឹងមិនអាចកើតមានឡើយ ប្រសិនបើគ្មានការទទួលយកនូវទំនើបកម្ម ជាពិសេសការសាងសង់មនុស្សដែលចរិកអន់មើលងាយអ្នកដទៃ ស្អប់ជាតិសាសន៍អ្នកដទៃដូចជាស្អប់ពួកphilistines ឬជាប្រប្រភេទមនុស្សថោកទាប ចូលចិត្តសជេរប្រមាថ និងគ្មានវប្បធម៌ ពោលទៅជាប្រភេទមនុស្សមានគុណធម៌ជាមុនសិន។[14]

វាជាការពិតដែលថាការសម្លាប់រង្គាលរបស់ណាហ្ស៊ី មិនមានផលប៉ះពាល់ផ្ទាល់លើជីវិតផ្ទាល់ខ្លួនរបស់ Bauman ប៉ុន្តែភរិយារបស់គាត់ Janina បានរងទុក្ខកាលពីនៅក្មេង ជាក្មេងស្រីជនជាតិជ្វីហ្វនៅ Warsaw ghetto។ Janina បានសរសេរអនុស្សាវរីយ៍ចូចត់របស់នាងនូវអត្ថបទ Winter in the Morning ដែលជំរុញឱ្យ Bauman ចាប់អារម្មណ៍លើការសម្លាប់រង្គាល ជាបង្អួចមើលទៅកាន់ភាពទំនើប ឬជាលទ្ធភាពមួយរបស់វា។ សំខាន់ជាងនេះទៅទៀត Bauman នៅក្នុងការសន្ទនាជាមួយ Anver Shapira រិះគន់ការបំពានរបស់អ៊ីស្រាអែល និង "ការធ្វើឯកជនភាវូបនីយកម្ម" នៃការសម្លាប់រង្គាលដោយលើកហេតុផលថា "ជនជាតិជ្វីហ្វអាចមានសុវត្ថិភាពតែនៅក្នុងពិភពលោកដែលមិនមានជាតិនិយម ហើយនោះរួមមានជាតិនិយមរបស់ជនជាតិជ្វីហ្វផងដែរ។"[15] ការប្រឆាំងរបស់ Bauman លើជំហរជាតិនិយមបង្ហាញនៅក្នុងសមាជិកភាពរបស់គាត់នៃក្រុមអង់គ្លេសដ៏ល្បីមួយហៅថា យុត្តិធម៌ជាតិជ្វីហ្វសម្រាប់ប៉ាឡេស្ទីន។ ក្រុមនេះសហការជាមួយក្រុមផ្សេងទៀតដូចជា ក្រុមអ្នកនិពន្ធប្រឆាំងនឹងអាណានិគម និងនិស្សិតជ្វីហ្វដើម្បីយុត្តិធម៌សម្រាប់ប៉ាឡេស្ទីន ដែលក្រុមទាំងអស់នេះជំរុញគំនិតថាគ្មានសង្ឃឹមឡើយសម្រាប់អ៊ីស្រាអែល បើគ្មានយុត្តិធម៌សម្រាប់ប៉ាឡេស្ទីននោះ។ នេះហើយជាមូលហេតុដែលពួកគេដឹកនាំការខិតខំប្រឹងប្រែងក្នុងការបង្កើតយុទ្ធនាការបញ្ចប់ការកាន់កាប់ ដែលមានមូលដ្ឋានដ៏ទូលំទូលាយ ដែលគាំទ្រសិទ្ធិរបស់ប៉ាឡេស្ទីន និងថ្កោលទោសការកាន់កាប់របស់អ៊ីស្រាអែលដោយខុសច្បាប់ ការតាំងទីលំនៅ និងការរំលោភបំពាន ដោយការបង្ខិតបង្ខំដោយយោធា និង

អំពើហឹង្សាប្រឆាំងនឹងប៉ាឡេស្ទីនដែលគ្មានអាវុធ និងមានភាពក្រីក្រ។ ការនិរទេសខ្លួនរបស់ Bauman ពីប្រទេសប៉ូឡូញបានដើរតួយ៉ាងសំខាន់ក្នុងការគូរវាសរបស់គាត់អំពីផលវិបាកនៃទំនើបកម្ម វាបានផ្តល់ឱ្យគាត់នូវគុណសម្បត្តិដែលមានភាពមិនសមរម្យ ដែលនាំឱ្យគាត់ផ្តោតលើមុខងាររបស់មនុស្ស ការនិរទេសខ្លួន និងអ្នកនៅខាងក្រៅ។ ស្នាដៃ Bauman បានដឹកនាំដោយបញ្ញាអត្ថិភាពនៃមនុស្សប្លែកទីទៃពីគ្នា ហើយគាត់បានសង្ខេបអំពីរបៀបរស់នៅប្រកបដោយបញ្ញានេះនៅក្នុងសេចក្តីថ្លែងការណ៍មួយដោយ Frederic Raphael, George Steiner និង Ludwig Wittgenstein ដែលមានអត្ថន័យរៀងៗខ្លួនៈ" (1) អត្ថន័យនៃខ្ញុំជាជនជាតិជ្វីហ្វគឺថាខ្ញុំនៅគ្រប់ទីកន្លែង" (2) "ស្រុកកំណើតរបស់ខ្ញុំគឺជាម៉ាស៊ីនអង្គុលីលេខរបស់ខ្ញុំ" និង (3) "កន្លែងតែមួយគត់ដែលបញ្ហាទស្សនវិជ្ជាពិតប្រាកដអាចត្រូវបានដោះស្រាយនិង ដំណោះស្រាយគឺស្ថានីយ៍រថភ្លើង។" [16]

នៅក្នុងស្នាដៃ Modernity and Ambivalence (1991) Bauman តាមដានការបរាជ័យនៃសង្គមសេរីនិយមនៃសម័យទំនើបរបស់លោកខាងលិច និងការសង្កត់ធ្ងន់ថា ជាតិនិយមផ្តាច់មុខមិនត្រូវបានបង្ខាំងទុកនៅក្នុងតែប្រទេសប៉ូឡូញប៉ុណ្ណោះនោះទេព្រោះវាបានបង្ហាញយ៉ាងច្បាស់ នៅក្នុងការបរាជ័យនៃមហិច្ឆតារបស់វានៅក្នុងបណ្តាប្រទេសអឺរ៉ុបស្ទើរតែទាំងអស់។ ដូចដែល Bauman ពិពណ៌នាវាពាក់ព័ន្ធនឹងការច្រានចោលនិន្នាការអាថ៌កំបាំង និងនិន្នាការមេស្ស៊ីមិនមែនជាជនជាតិជ្វីហ្វ ដោយផ្តល់ភាពជឿជាក់នៃការកែតម្រូវវប្បធម៌តែចំពោះទំនាក់ទំនងផ្នែកខាងក្រៅប៉ុណ្ណោះៈ Bible of Luther, Hermann Cohen និង Kant, Steinthal និង Wilhelm von Humboldt។ ដូច្នេះជនជាតិជ្វីហ្វភាគច្រើនត្រូវបានលើកទឹកចិត្តឲ្យទទួលបាន "អាកប្បកិរិយាពីការចម្រាញ់" និងស្តង់ដារថ្មីនៃ "ការសម្អាត" ។ ការអំពាវនាវឱ្យមាន "ភាពស្អាតស្អំ" ខាងរាងកាយ និងសីលធម៌ត្រូវបានអមជាមួយនឹងការអំពាវនាវឱ្យមានភាពស្អាតស្អំខាងភាសា ហើយភាសា Yiddish ដែលជាភាសារបស់ Ostjuden (ជនជាតិជ្វីហ្វនៅអឺរ៉ុបខាងកើតមកពីប្រទេសរុស្ស៊ី ប៉ូឡូញ អ៊ុយក្រែន និង Galicia) បានក្លាយជាគោលដៅនៃការចំអកក្នុងចំណោមជនជាតិជ្វីហ្វនៅអាល្លឺម៉ង់។ ដូចជាភាសា Yiddish ភាសាប៉ូឡូញត្រូវបានគេមើលងាយថាជាភាសាមានឋានៈទាបជាងភាសាអាល្លឺម៉ង់។ Ostjuden ត្រូវបានគេចាត់ទុកថាជា "អ្នកផ្ទុកជំងឺ និងការរាតត្បាត" "ពួកព្រៃផ្សៃ ល្ងង់ខ្លៅ និងអសីលធម៌" និង "អ្នកចម្លែកដែលមិនគួរឱ្យស្វាគមន៍"។[17]

ការវិភាគរបស់ Bauman អំពីប្រវត្តិសាស្ត្រនៃការរួមបញ្ចូលសាសន៍ជ្វីហ្វនៅភាគខាងលិចគឺទាក់ទងយ៉ាងជិតស្និទ្ធ និងការកំណត់ប្រឆាំងនឹងគំរូនៃ Ostjude ដែលមិនស៊ីសង្វាក់គ្នា ដែលជាសាសន៍ជ្វីហ្វនៅអឺរ៉ុបខាងកើត និងកណ្តាល។ លោក Bauman ប្រកាន់ខ្ជាប់ថាស្នាដៃHolocaust មានការប្រែប្រួលច្រើនលើអត្ថន័យនៃសាសនាជ្វីហ្វ ដោយសារអ្នកទ្រឹស្តីខ្លះបានចាត់ទុកវាជាសញ្ញានៃ "អវត្តមាននៃព្រះ" "ការបរាជ័យនៃព្រះ" "ប្រពៃណីការនិរទេសរបស់ជនជាតិជ្វីហ្វ" និងជម្រើសរបស់ជនជាតិជ្វីហ្វជា "អ្នកពាំនាំសេចក្តីពិត" នៃអរិយធម៌ទំនើប។ ចាប់តាំងពីពាក់កណ្តាលសតវត្សរ៍ទី១៩មក ប្រទេសបារាំង អង់គ្លេស និងរុស្ស៊ីបានដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការលុបបំបាត់ការកើនឡើងនៃចំនួនជនក្រីក្រដែលមិនបានសិក្សា និងជនអន្តោប្រវេសន៍ជ្វីហ្វដែលគ្មានអរិយធម៌ ដែលមានជម្រើសសំខាន់២នៃការសង្គ្រោះៈ ស៊ីយូនីសជ្វីហ្វនិយម និងសង្គមនីយម។ នៅប្រទេសប៉ូឡូញ ស្ថាន

ការណ៍កាន់តែអាក្រក់ទៅៗ ដោយសារមានជំនឿយ៉ាងមុតមាំថា ជនជាតិជ្វីហ្វគឺជាមនុស្សខាងក្រៅ និងមានជាតិពុលនៅក្នុងសារពាង្គកាយនៅប្រទេសប៉ូឡូញដែលកំពុងលេចចេញឡើង។[18]

អ្វីដែលគួរឱ្យសោកស្តាយបំផុតនោះគឺថា ភាពជោគជ័យរបស់បុគ្គលស្ទើរតែគ្រប់មជ្ឈដ្ឋាន មិនមែនជាការធានាគ្រប់គ្រាន់នៃសមភាពនយោបាយ និងការទទួលយកសង្គមនោះទេ។ នៅក្នុងនាមជាជាតិសាសន៍មួយដែលគ្មានរដ្ឋ សហគមន៍ជ្វីហ្វនៅអឺរ៉ុបមានការប៉ុនប៉ងដើម្បីទទួលបាន "អធិបតេយ្យភាពដូចរដ្ឋ"ប៉ុន្តែការបរាជ័យនៃមហិច្ឆតានេះបាននាំឱ្យនៅក្នុងការវិភាគចុងក្រោយចំពោះការលេចចេញនៃនយោបាយ ស៊ីយនីសជ្វីហ្វនិយម និងវត្ថុបំណងរបស់ខ្លួននៃ "រដ្ឋសេរីនិយមរបស់សាសន៍ជ្វីហ្វ"៖

> មានការសង្ស័យតិចតួចដែលថាកំណើតនៃស៊ីយូនិស ជ្វីហ្វនិយម ជានយោបាយពិតប្រាកដបំផុត នៅក្នុងផលវិបាកបំផុតរបស់វា កំណែប្រែរបស់ Herz គឺជាលទ្ធផលនៃការបែកបាក់នៃកិច្ចខិតខំប្រឹងប្រែងជាជាងផលផ្លែនៃប្រពៃណីសាសនាជ្វីហ្វ និងការរស់ឡើងវិញនៃសេចក្តីស្រឡាញ់នៃជ្វីហ្វនិយម។[19]

## ជំពូកទី២
## វ៉ាឌីកាល់នៃការត្រាស់ដឹង

ពាក្យប្រៀបធៀបនៃវឌ្ឍនភាព តាមទស្សនៈរបស់ Bauman បានប្រែក្លាយ eschatology metaphysical ទៅជាកំណែប្រែខាងលោកិយដែលមិនស្ថិតស្ថេរក្នុងប្រវត្តិសាស្ត្រ។ ទស្សនវិទូ Les បានឈ្លក់វង្វេងនឹងគំនិតនៃវឌ្ឍនភាព ដោយសារ "វប្បធម៌ទំនើបគឺជាវប្បធម៌លម្អដូចជាសួនច្បារ។ វាកំណត់ដោយខ្លួនវាថាជាការរចនាសម្រាប់ជីវិតដ៏ល្អមួយ និងការរៀបចំដ៏ល្អឥតខ្ចោះនៃលក្ខខណ្ឌរបស់មនុស្ស" [1] ភាពទំនើបនិយម មិនដូចការគ្រប់គ្រងដ៏យូររបស់គ្រិស្តសាសនា "វាបានបដិសេធការជឿជាក់នឹងជីវិតក្រោយពេលស្លាប់ ដោយផ្តោតលើជីវិត "នៅទីនេះ និងឥលូវនេះ" សកម្មភាពជីវិតកើតឡើងវិញជុំវិញរឿងផ្សេងៗ ជាមួយនឹងគោលដៅ និងតម្លៃនៅលើផែនដី និងទាំងអស់គ្នាបានព្យាយាមបំបាត់ភាពភ័យខ្លាចនៃសេចក្តីស្លាប់"។[2]

Bauman ណែនាំពាក្យប្រៀបធៀបដ៏សំខាន់ដែលបង្ហាញពីការយល់ដឹងរបស់គាត់អំពីភាពទំនើបជាមូលដ្ឋាន៖ "អ្នកគ្រប់គ្រងនៅសម័យទំនើប និងទស្សនវិទូសម័យទំនើបគឺជាសមាជិកសភាដំបូង និងសំខាន់ជាងគេ។ ពួកគេរកឃើញភាពចលាចល និងបានចេញទៅបង្កើតបញ្ហា និងជំនួសវាដោយការមានរបៀបរៀបរយ"[3] សមាជិកសភាមិនមែនជាមនុស្សធម្មតាទេ ប៉ុន្តែជាបុរសរដ្ឋដែលអាចឆ្លងផុតពីការពិតដែលមានស្រាប់ ហើយពិនិត្យមើលវាពីខាងក្រៅដោយប្រើការក្រឡេកមើលពីចម្ងាយរបស់ពួកគេ។[4] ពាក្យប្រៀបធៀប "អ្នកថែសួន" និង "អ្នកបង្កើតច្បាប់" គឺសំដៅលើទំនាក់ទំនងដ៏ស្មុគស្មាញរវាងវប្បធម៌ និងអំណាច។ Richard Kilminster និង Ian Varcoe រកឃើញគំរូនេះនៅក្នុងស្នាដៃរបស់ Baumanដោយបង្ហាញពីរបៀប ដែលគាត់មើលឃើញភាពទំនើបជារចនាសម្ព័ន្ធទូទៅ ឬលំដាប់លំដោយ និងរបៀបដែលការជំរុញឱ្យមានរចនាសម្ព័ន្ធតែងតែបង្កើត "បញ្ហា" ថ្មី។

Baumanសង្កត់ធ្ងន់ថាហេតុផលត្រូវបានទទួលយកដោយបញ្ញវន្តនៃការយល់ដឹង ក្នុងគោលបំណងលើកកម្ពស់ការរំដោះមនុស្ស និងដើម្បីបំបាត់ការរើសអើង អវិជ្ជា អបិយជំនឿ និងលទ្ធិទុច្ចរិត។ ការហួសចិត្តដ៏សោកសៅបំផុតគឺថាវាបានដឹកនាំនៅក្នុងការវិភាគចុងក្រោយទៅកាន់ «ចំណងថ្មី» «ភេរវកម្ម»និង«ចំណេះដឹងផ្តាច់មុខ»។ Bauman ជឿថា ចក្ខុវិស័យសេរីនៃការរួមបញ្ចូលវប្បធម៌គឺជាផ្នែកមួយនៃភាពផ្ទុយគ្នាដ៏សំខាន់នៃសម័យទំនើប ពីព្រោះ "ល្បែងនៃការរំដោះខ្លួន តាមពិតគឺជាល្បែងនៃការត្រួតត្រាពេលដើម្បីគ្រប់គ្រង"។ ការហួសចិត្តដែលវាស្ថិតនៅចំកណ្តាលនៃបញ្ហានេះគឺថា ការរំដោះខ្លួនមិនមែនជាការអំពាវនាវឱ្យមានភាពចម្រុះ ការផ្លាស់ប្តូរវប្បធម៌ ការសាយភាយវប្បធម៌ ឬពហុនិយមនោះទេ ប៉ុន្តែជាការអំពាវនាវឱ្យមានឯកសណ្ឋាន ភាពដូចគ្នា និងការបង្រួបបង្រួមយ៉ាងទូលំទូលាយនៃប្រជាជន។ ការតម្រង់ទិសនេះបាននាំឱ្យមានបរិយាកាសកាន់តែច្រើនឡើងនៃ "ការមិនអត់ឱនចំពោះភាពខុសគ្នាទៅវិញ"[7]។

Bauman លាតត្រដាងពីគំនិតដែលជំរុញទឹកចិត្ត ផ្ទុយពីលោកិយដ៏លេចធ្លោនូវជំនឿលោកខាងលិចនិងអាប់ ដែលថាគម្រោងEnlighmentចលនាចំណេះដឹងពេលនៅសតវត្សរ៍ទី១៧ និង១៨មិនមែនជាសុបិន្តដ៏ថ្លៃថ្នូនៃការរីករាលដាលពន្លឺនៃប្រាជ្ញា និងសេរីភាពនោះឡើយ។ ផ្ទុយទៅវិញ វាមានគោលបំណងលើកកម្ពស់មហិច្ឆតារបស់រដ្ឋ និងបង្កើត "យន្តការសង្គមនៃសកម្មភាពដែលមានវិន័យ"។ការត្រាស់ដឹង ឬចលនាចំណេះដឹងនៅសតវត្សរ៍ទី១៧ និង១៨ មិនត្រូវបានគេមើលឃើញថាជាការប្រៀបធៀបសម្រាប់ពន្លឺ សេរីភាព ការបំភ្លឺហេតុផល និងសេរីភាព។ ចលនានៃចំណេះដឹងនេះបានគូរផែនទីដោយ Bauman បង្ហាញពី "ហេតុផលនៃមធ្យោបាយ និងអំពើភេរវកម្ម" ក៏ដូចជា "ការរើសអើងជាតិសាសន៍នៃបញ្ញវន្ត"។[9]

ចំពោះលោក Elmessiri គាត់យល់ឃើញពីរ៉ាឌីកាល់ ឬចលនាចំណេះដឹងនៃសតវត្សរ៍ទី១៧ និង១៨ ជា "មូលដ្ឋានទស្សនវិជ្ជានៃលទ្ធិលោកិយនិយមដ៏ទូលំទូលាយ"[10] ដោយលើកហេតុផលថា ចលនាចំណេះដឹងបានឈានទៅដល់សម័យកាលបែបមនោគមវិជ្ជា និងសនិទានភាពនៅក្នុងគំនិតនៃសព្វវចនាធិប្បាយបារាំងសតវត្សរ៍ទី១៨។ មិនគួរឱ្យភ្ញាក់ផ្អើលទេដែលគាត់បានផ្តោតតែលើទស្សនវិជ្ជាសម្ភារៈនិយមរបស់ពួកគេដែលឆ្លុះបញ្ចាំងពីយន្តការ / ឬគំរូរូបរាងនៃការត្រាស់ដឹង ឬចលនាចំណេះដឹងនេះ។ ម្យ៉ាងវិញទៀត ការបង្ហាញពីរ៉ាឌីកាល់នៃការត្រាស់ដឹងត្រូវបានពិភាក្សា ដោយយោងទៅលើការសរសេរអំពីពិភពលោកថាជាយន្តការ /ឬអត្ថិភាពរបស់វាដែលមានដូចជា៖ La Mettrie's Histoire naturelle de l'âme (1745) និង L'Homme machine (1748); Claude Adrien Helvétius's De l'Esprit (1758) និង De l'Homme (1773) ប្រព័ន្ធ Paul d'Holbach's Système de la nature ou des loix du monde physique & du monde moral (1770) របាយការណ៍របស់ Pierre Jan Cabanis du physique et du moral de l'homme (1802) និង Marquis de Condorcet's Esquisse d'un tableau historique des progrès de l'esprit humain(1795)។[11]

ការរិះគន់របស់ Elmessiri ចំពោះចលនាចំណេះដឹងសតវត្សរ៍ទី១៧ និង១៨មានច្រើនដូចគ្នាជាមួយការវាយប្រហារដ៏កាចសាហាវបានចាប់ផ្តើមនៅក្នុងប្រវត្តិសាស្ត្រនៅសតវត្រ៍សទី20 ប្រឆាំងនឹងអ្នកសម្ភារៈនិយមជាទូទៅ និង Julien Offray de La Mettrie (1709-1751) ជាពិសេស។ Les

philosophes ជាក្រុមត្រូវបានចោទប្រកាន់ថាជាទទួលខុសត្រូវចំពោះការកើនឡើងនៃរដ្ឋផ្តាច់ការ ជំងឺនៃសតវត្សរ៍ទី20 និងចលនាប្រឆាំងគ្រប់ជំនឿសាសនាទាំងអស់ នៅក្នុងសកលលោក។ កេរដំណែលនៃចលនាចំណេះដឹងសតវត្សរ៍ទី១៧ និង១៨ ត្រូវបានកាត់បន្ថយទៅជាទិដ្ឋភាពនៃសង្គមសម្ភារៈនិយមដែលបង្ហាញយ៉ាងល្អនៅក្នុងស្នាដៃជាមូលដ្ឋានរបស់ La Mettrieទៅ លើទស្សនវិជ្ជានៃធម្មជាតិ ៖ L'Histoire naturelle de l'âme, L'Homme machine, L'Homme plante និង Le Système d'épicure។ ការបដិសេធរបស់ពួកសម្ភារៈនិយម ឬលោកិយនិយមថាជា "អ្នកបោសសំអាតគំនិតនៃសភាវៈអាក្រក់" ត្រូវបានសន្មតថាជាការពិតដែលថាពួកគេត្រូវបានជ្រើសរើសដោយលោកកាលម៉ាក្សដូច្នេះធ្វើឱ្យវាងាយស្រួលសម្រាប់អ្នកប្រវត្តិសាស្ត្រក្នុងការធ្វើឱ្យពួកគេទទួលខុសត្រូវចំពោះជំងឺ នៃសតវត្សទី20 ការអនុវត្តនៃរបបកុម្មុយនិស្ត។ ការកើនឡើងនៃរដ្ឋាភិបាលផ្តាច់ការ និងវិនាសកម្មមនុស្សជាតិពេលនាសម័យកាលនោះ។[12]

ទិដ្ឋភាពនេះអាចត្រូវបានគេមើលឃើញថាគ្មានអ្វីក្រៅពីការកាត់បន្ថយភាពទំនើប"ផ្នែកងងឹតនៃសង្គមទំនើប" ដែលត្រូវបានរំពឹងទុកដោយ MaxHorkheimer និង Theodor Adorno នៅក្នុង Dialectic of Enlightenment ដែលបោះពុម្ពដំបូងក្នុងឆ្នាំ1944 ក្រោមចំណងជើងថា Philosophische Fragmente។ ការរិះគន់នេះ ក្រោយមកត្រូវបាននាំយកទៅរិះគន់យ៉ាងខ្លាំងដោយ Herbert Marcuse នៅក្នុងស្នាដៃ One-Dimensional Man របស់គាត់(1964)។ Elmessir អាចចោទប្រកាន់យ៉ាងងាយស្រួលថា វាត្រូវបានរងការជះឥទ្ធិពលដោយការរិះគន់លើវប្បធម៌សោកនាដកម្ម និងទុទិដ្ឋិនិយមនៃសាលា Frankfurt, ការរិះគន់របស់ Weberian អំពីហេតុផលនិយម និងពាក្យប្រៀបធៀបជាទ្រុងដែក នៃភាពទំនើប និងភាពច្របូកច្របល់នៃពិភពលោក។ ដូចដែលលោក Bernstein បានបង្ហាញ យើងអាចមើលឃើញយ៉ាងច្បាស់ថាអ្នករិះគន់សតវត្សរ៍ទី20 នៃចលនាចំណេះដឹងសតវត្សរ៍ទី១៧ និង១៨ និងសនិទាននិយម "អាចត្រូវបានយល់ថាជាការបម្រែបម្រួលពេលលើគំនិតបញ្ញវន្ត និងមហាជន" ។[13] វាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែល Elmessiri បានចំណាយជំពូកទាំងមូលរបស់គាត់នលើសៀវភៅសិក្សាអំពីសម័យទំនើបរបស់លោកខាងលិច ចំពោះភាពជាតំណាង និងការវិភាគនៃទ្រឹស្តីនៃសនិទានកម្មរបស់Weber ។ ដូច្នេះ Elmessiri គឺកៀកកិតនឹងការរិះគន់លោកខាងលិចទាំងអស់ដែលបានព្យាករណ៍ថាសតវត្សរ៍ទី20 នឹងក្លាយជាយុគសម័យនៃសនិទានកម្មដែលធ្វើអាណានិគម ពោលដោយពួកអ៊ឺរ៉ុបលើជាតិសាសន៍ដទៃ និងផ្លាស់ប្តូរជីវិតប្រចាំថ្ងៃរបស់យើង។

## ជំពូកទី៣
## ទំនើបកម្មប្រៀបដូចជានិទានកថា

នៅក្នុងវ័យកុមារភាព Elmessiri ធ្លាប់ទៅបណ្ណាល័យ ហើយគាត់បានឃើញជាលើកដំបូងនូវពាក្យ "Gnosticism" នៅក្នុងសៀវភៅមួយរបស់ Abdul Rahman Badawi សម្លេង និងភាពចម្លែកនៃពាក្យនេះបានធ្វើឱ្យគាត់ញ័រខ្លួនរហូតដល់គាត់បន្តគិតអំពីវាពេញមួយជីវិតរបស់គាត់។ នៅក្នុងភាគទីពីរនៃ Mawsu at al-Falsafah (សព្វវចនាធិប្បាយទស្សនវិជ្ជា) Badawi រួមបញ្ចូលនូវសមាសជាតុ monism និងpantheism និងបានចំណាយ៤ទំព័រនៅលើ Gnosticisms ដែលគាត់បានកំណត់ថាជា

"ការតម្រង់ទិសសាសនាអាចកំបាំង និងទស្សនវិជ្ជា។ Gnosisឬជីណូហ្ស៊ីសគឺចលលនាសាសនាគ្រីស្ត នៅសតវត្សរ៍ទី២ ដែលមានទ្រឹស្តីថា ព្រះគឺជាផ្លូវទៅកាន់សេចក្តីសង្គ្រោះ ពីព្រោះព្រះគឺជាមនុស្សលោក។ មូលដ្ឋាននៃ gnosis ជីណូហ្ស៊ីស គឺជាការដឹងខ្លួនរបស់មនុស្សលោកនូវចំណេះដឹងនាំទៅរកសេចក្តីសង្គ្រោះសម្រាប់មនុស្ស" [1] ប្រហែលជានិយមន័យនេះបានជួយឱ្យស្នាដៃរបស់ Elmessiri វេទ្ធាយបន្តិចពីទិដ្ឋភាពពិតពអ៊ីស្លាមពី Gnosticism ដោយបោះបង់ចោលភាពទំនើប និងលទ្ធិលោកិយនិយមត្រឡប់ទៅរកកេរដំណែលនៃសាសនាដែលខុសឆ្គងនៅក្នុងសាសនាគ្រីស្តនាសម័យបុរាណ។ Elmessiri បានមើលឃើញថា Gnosticism គឺជាទម្រង់លេចធ្លោបំផុតនៃ Immanentism និង pantheismដែលទាំងពីរនេះត្រូវបានតំណាងថាមិនស៊ីសង្វាក់គ្នាជាមួយទស្សនៈពិតពmonotheistic សុទ្ធសាធនោះឡើយ។ Immanence គឺស្ទើរតែមានន័យដូចទៅនឹង pantheism និងលោក Elmessiri មិនឃើញមានភាពខុសគ្នាជាមូលដ្ឋានរវាងពួកគេទេ ប៉ុន្តែគាត់ជ្រើសរើសពាក្យនីមួយៗទៅតាមបរិបទ។ Gnosticism តាមទស្សនៈរបស់ Elmessiri បានចាប់ផ្តើមជាទម្រង់មួយនៃ pantheism ខាងសមាធិផ្នែកវិញ្ញាណរហូតដល់សតវត្សរ៍ទី១៨ និងបន្ទាប់មកបានផ្លាស់ប្តូរទៅជា pantheism សម្ភារៈនិយមនៅក្នុង Kabbalah ដែលជាទស្សនវិជ្ជានៃ Spinoza និង Hegel និងសម័យទំនើបនៃលទ្ធិលោកិយនិយមដ៏ទូលំទូលាយ។ នៅដំណាក់កាលដំបូងនៃការសរសេរ Mawsu at al-Falsafah របស់គាត់ Elmessiri បានចំណាយ២៣បន្ទាត់ប៉ុណ្ណោះចំពោះជាតុ Spinoza ពោលទស្សនវិជ្ជារបស់ហូឡង់នៅសតវត្សរ៍ទី២ ប៉ុន្តែនៅពេលដែលគំរូនៃភាពមិនចេះប្រែប្រួលនៅក្នុងចិត្តរបស់ Elmessiri ក្នុងទសវត្សរ៍ឆ្នាំ1990 ជាតុ Spinozaត្រូវបានពង្រីក និងពន្លាតទៅទំព័រជាច្រើនផ្សេងទៀត។

ការរិះគន់របស់ Bauman មានច្រើនដូចគ្នាទៅនឹង Elmessiri ការបញ្ចប់នូវការទទួលស្គាល់ព្រះ និង "អ្វីដែលគេហៅថាលោកិយនិយម" បានបង្កើតឱ្យមានតួអង្គព្រះថ្មីសម្រាប់លោកិយនិយម រួមទាំងថែមទាំងធម្មជាតិ ច្បាប់នៃប្រវត្តិសាស្ត្រ ហេតុផល និងវឌ្ឍនភាពផងដែរ។ តួអង្គថ្មីតំណាងថា ព្រះ បានទទួលការបង្កប់ន័យ និងអត្ថន័យថ្មី ដែលហួសពីជម្លោះខាងទ្រឹស្តីអំពីវត្តមាន ឬអត្ថិភាពនៃព្រះ។ ព្រះមិនបានត្រាស់ដឹងទេ ហើយទ្រង់បានចាប់បដិសន្ធិក្នុងប្រភេទដែលមិនមែនជាបុគ្គល ដូចជាហេតុផល ច្បាប់នៃប្រវត្តិសាស្ត្រប្រៀបដូចជាដៃ ដែលមើលមិនឃើញ ឬភាពជៀសមិនរួចពីប្រវត្តិសាស្ត្រ។[2] Monism និងភាពផ្តាច់មុខនៃសេចក្តីពិត មិនដែលចាកចេញពីទីតាំងនៃកន្លែងកើតឡើងនៃហេតុនោះឡើយ៖

> ព្រះតំណាងឲ្យគំនិត មានតែមួយ សម្រាប់អ្នកនឹងគ្មានព្រះផ្សេងទៀតទេ។គំនិតរបស់ខ្ញុំនៅចំពោះមុខខ្ញុំក្នុងការបង្ហាញ និងផ្នែកខាងក្រៅរាប់មិនអស់របស់វា៖ ein Volk, ein Reich, ein Führer នៃផ្នែកមួយ សាលក្រមមួយនៃប្រវត្តិសាស្ត្រ ផ្នែកមួយនៃវឌ្ឍនភាព របៀបនៃភាពជាមនុស្ស មនោគមវិជ្ជាមួយ (វិទ្យាសាស្ត្រ) អត្ថន័យពិតមួយ និង ទស្សនវិជ្ជាត្រឹមត្រូវមួយ។ នៅក្នុងករណីទាំងអស់បែបនេះ មានតែមួយ វាបង្ហាញសារតែមួយ សិទ្ធិក្នុងភាពផ្តាច់មុខនៃអំណាចសម្រាប់អ្នកខ្លះ និងកាតព្វកិច្ចនៃការមិនស្តាប់បង្គាប់ទាំងស្រុងចំពោះអ្នកដទៃ។

ដូច Bauman ដែរ Elmessiri បានមើលឃើញភាពទំនើបជាលំដាប់លំដោយមួយដែលចាប់ផ្តើមដោយអនិតិកម្មដោយផ្នែក (ផ្នែកខាងលោកិយនិយម) និងបញ្ចប់ដោយភាពមិនប្រាកដនិយមដ៏ធំទូលំទូលាយ (លោកិយនិយមដ៏ធំទូលាយ)។ គាត់បានបដិសេធរាល់គំរូនៃការកាត់បន្ថយ និងនិស្ស័យនិយមទាំងអស់ដែលសន្មតថាចលនា និងការបញ្ចប់នៃប្រវត្តិសាស្ត្រមានតែកម្លាំងតែមួយគត់ មិនថាខាងវិញ្ញាណស្មារតី ឬសម្ភារៈនិយមនោះឡើយ។ Elmessiri បានឃើញដំណើរការទាំងមូលនៃ immanentizationភាវូបនីយកម្មនៃទស្សនវិជ្ជាហូឡង់ / ទំនើបភាវូបនីយកម្ម / លោកិយនិយម នៅក្នុងលក្ខខណ្ឌនៃការចាប់បន្តិសន្ទិខាងលោកិយនៃព្រះនៅក្នុងសង្គមមនុស្សជាតិទាំងមូល (មនុស្សជាតិនិងប្រធានបទ solipsistic); នៅក្នុងសង្គមមនុស្សតែមួយ (ការរើសអើងជាតិសាសន៍និងចក្រពត្តិនិយម) នៅក្នុងក្រុមអ្នកដឹកនាំមួយ (ហ្សាហ្ស៊ីសនិយម) និងនៅក្នុងធម្មជាតិ (pantheism) បញ្ជាក់ថាមិនមានការខ្វះខាតលើការមានវត្តមាន និងសញ្ញាផ្សេងទៀតនោះឡើយ។[4]

Elmessiri និងBauman បានបដិសេធថារាល់ជាតិនិយម និងចលនាមនោគមវិជ្ជាជាទម្រង់នៃទស្សនវិជ្ជាimmanentization និងរួបរួមនិយម/ យន្តការគំរូនិយម។ ទោះបីជាយ៉ាងណាក៏ដោយ ជំហរ និងការវិភាគរបស់ Elmessiri គឺកាន់តែច្បាស់លាស់នឹងការសម្រេចចិត្ត និងមានភាពទូលំទូលាយ នៅពេលដែលគាត់បញ្ជាក់ថា ចលនាបែបនេះនឹងធ្វើអ្នកប្រកាន់ខ្ជាប់ ពោលឲ្យតម្លៃតែលើ" ការបញ្ចប់នៃការតស៊ូ និងការបង្កើតសង្គមបច្ចេកវិទ្យា មិនថានៅក្នុងស៊ីយ៉ូនីសជ្វីហ្វនិយម នាយទុនសង្គមកិច្ចលោកខាងលិច សង្គមកុម្មុយនិស្តក៏ដោយ។"[5] មនោគមវិជ្ជាទំនើបត្រូវបានពណ៌នាថាមិនបង្ហាញអ្វីក្រៅពី "ជាអាណាចក្រនៃសកម្មភាពរបស់មនុស្ស" និង "ឆន្ទៈធ្វើឱ្យមានជីវិត" ពីព្រោះរាល់ចលនានៃទស្សនវិជ្ជា gnostic ព្យាយាមលុបចោលធម្មនុញ្ញនៃភាពមានប្រភពដើមពីទេវភាព ភាពអស្ចារ្យ និងដើម្បីជំនួសវាដោយពិភពលោកដោយអចិន្ត្រៃយ៍នោះឡើយ។[6]

ការយល់ដឹងរបស់ Elmessiri អំពីទំនើបកម្មលោកខាងលិច ក៏ដូចជាការយល់ដឹងទ្វេរដងរបស់គាត់អំពីភាពខុសគ្នារវាងបរិបទទស្សនវិជ្ជាimmanence និងវិចារណញ្ញាណ គឺផ្អែកលើការបដិសេធរបស់គាត់ចំពោះ pantheism ដែលលេចឡើងក្នុងឈ្មោះផ្សេងៗគ្នានៅក្នុងវចនានុក្រមអារ៉ាប់និងអ៊ីស្លាម។ រួមមាន Alwihdat al-wujud(ការរួបរួមនៃម៉ាឃ្លោក) Hulul (ស្ថិតនៅ)Fana (វិនាសកម្មដ៏ធំធេង)

ដែលទាំងអស់នេះមានគោលបំណងទៅលើ "ការស្រូបចូលឲ្យបានពេញលេញនៃចំពោះមនុស្សទៅក្នុងការមានជំនឿ" ដំណាក់កាលដែល Elmessiri ពិពណ៌នាថាប្រៀបដូចជា"ស្ថានភាពអំប្រ៊ីយ៉ុង" ពោលផ្តើមដំបូង និងជា "ការកកើតសរីរាង្គ" ចុងក្រោយ ដែលផ្ទុយពីស្ថានភាពនៃភាពពេញលេញរបស់មនុស្សជាតិ និងមានភាពស្មុគស្មាញ។[7] Elmessiri សំដៅទៅលើការប្រែប្រួលការវិវត្តទាំងនេះថាជារបៀបប្រៀបដូចជាការសន្លប់ ប៉ុន្តែមានភាពរីករាយ ដែលវាធ្វើឱ្យភាពសុខស្រួល និងការស្ថិតនៅរបស់កូនក្នុងផ្ទៃរបស់ម្តាយ។ បញ្ហាគឺបញ្ហាតូចៗទាក់ទិនប្រៀបដូចជា (ទារក នឹងសុក) និង បញ្ហាធំទូលំទូលាយប្រៀបដូចជា (រចនាសម្ព័ន្ធនយោបាយ) ជាដើម។ Elmessiri មិនស្ទាក់ស្ទើរក្នុងការពិពណ៌នាអំពីសង្គមនយោបាយ និងបច្ចេកវិទ្យាថាជា "បំណងប្រាថ្នាពិតប្រាកដ និងដោយស្មោះដើម្បីស្វែងរកដំណោះស្រាយចុងក្រោយចំពោះបញ្ហាទាំងអស់ ដើម្បីបង្កើតឋានសួគ៌នៃពិភពលោក និងបញ្ចប់ប្រវត្តិសាស្ត្រ។"

ក្នុងនាមជាអ្នករចនានៃសង្គមដ៏ល្អឥតខ្ចោះ ពួកណាហ្ស៊ីសបានបង្កើត គោលដៅមូលដ្ឋានដែលត្រូវតែឃ្លាតឆ្ងាយពីគ្នា បង្កើតបានជា lebensraum ពោលគឺការនាំរទេសចេញ ធ្វើការបំបែកចេញពីគ្នា ឬសូម្បីតែត្រូវសម្លាប់ចោលក៏មានផងដែរ។[9] Unwetes Leben រួមមាន ជាតិgypsie ក្រុមកុម្មុយនិស្ត មនុស្សវិកលចរិត និងអស់អ្នកដែលត្រូវបានគេយល់ថាជាស្មៅដែលបង្កគ្រោះថ្នាក់គំរាមកំហែងដល់ភាពសុខដុមរមនាសួននៃសង្គមសម័យទំនើប។ ជនជាតិជ្វីហ្វ៦លាននាក់ស្ថិតក្នុងចំណោមមនុស្សជាង២០លាននាក់ដែលត្រូវបានគេសម្លាប់តាមការបង្គាប់របស់ហ៊ីត្លែរ។ មិនគួរឱ្យភ្ញាក់ផ្អើលទេ Bauman មិនគិតពីការសម្លាប់រង្គាលជាកិច្ចការតែទៅលើសាសន៍ជ្វីហ្វ ឬជាបញ្ហារបស់អាល្លឺម៉ង់នោះទេ ប៉ុន្តែជាលទ្ធភាពមួយនៃលទ្ធភាពមកពីភាពទំនើបនិយម។ វាគឺច្រើនជាងប្រៀបដូចជា "ការរីកលូតលាស់នៃជំងឺមហារីកលើរាងកាយដែលមានសុខភាពល្អ ប្រៀបដូចជានៅក្នុងសង្គមស៊ីវិល័យ។"[10] ជនជាតិហ្គីបសីមិនដូចជនជាតិជ្វីហ្វទេដោយមិនមានសាស្ត្រាចារ្យ អ្នកនិពន្ធ និងអ្នកសារព័ត៌មានច្រើនទេ។ ដើម្បីបង្ហាញពីទុក្ខលំបាករបស់ពួកគេ និងការតស៊ូមតិសិទ្ធិរបស់ពួកគេនោះឡើយ។[11]

## ជំពូកទី៤
## ការធ្វើផែនទីពីផលវិបាកនៃភាពទំនើប

Bauman បដិសេធចក្ខុវិស័យចក្រពត្តិនិយមលោកខាងលិចដែលព្យាយាមបំប្លែង "ទឹកដីដើម" ទៅជា "ទឹកដីដែលត្រូវបោះចោលសម្រាប់អ្នកដែលមិនចង់បាន និងចូលទៅក្នុង "ទឹកដីនៃការសន្យា" សម្រាប់អ្នកជំរុញវឌ្ឍនភាព។ ប្រជាជននៃទឹកដីដែលត្រូវបានសញ្ជ័យ ឈ្លានពាន និងដាក់អាណានិគមត្រូវបានចាត់តាំងឡើងវិញថាជា"អ្នកការពារសមូហភាពនៃទីក្រុងធំៗ"។[1] វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានលើកកម្ពស់ជំនឿយ៉ាងមុតមាំលើឧត្តមភាពនៃទំនើបកម្មរបស់លោកខាងលិច និងការកើនឡើងដែលមិនអាចជៀសបានរបស់វា ពោលគឺគំនិតនៃភាពទំនើបជាចំណុចខ្ពស់បំផុតនៃការអភិវឌ្ឍដែលផ្ទុយទៅនឹងគំនិតនៃវប្បធម៌។ ផែនទីការយល់ដឹងនេះបានធ្វើឱ្យភាពទំនើបនិយមលោកខាងលិចក្លាយជាទីតាំងឆ្លងពីអាជ្ញាធរទាំងអស់។ ឧទាហរណ៍ដូចជា វាបានក្លាយជាតំបន់ស្វ័យភាព គ្រប់គ្រង និងផ្ទៀងផ្ទាត់ដោយខ្លួនឯង។[2]

Bauman ប្រកែកថាសារៈសំខាន់នៃវិនាសកម្មសម្រាប់សង្គមវិទ្យានឹងត្រូវបានគេមើលងាយ វាយតម្លៃខុស ហើយត្រូវបានចាត់ទុកថាជាមធ្យោបាយ ប្រសិនបើ វិនាសកម្មនេះ ត្រូវបានគេមើលឃើញថាជា "អ្វីមួយដែលបានកើតឡើងចំពោះជនជាតិជ្វីហ្វ" ជា "ព្រឹត្តិការណ៍មួយនៅក្នុងប្រវត្តិសាស្ត្រជ្វីហ្វ" ឬជា "ព្រឹត្តិការណ៍ស្រដៀងគ្នាជាច្រើន" ករណីនៃជម្លោះ ឬការរើសអើង ឬការឈ្លានពាន។ សំខាន់ជាងនេះទៅទៀត Bauman គូសបញ្ជាក់ការពិតនោះ។ ការប្រឆាំងនឹងជនជាតិអាល្លឺម៉ង់តែម្នាក់ឯង មិនអាចជាការពន្យល់គ្រប់គ្រាន់អំពី វិនាសកម្មនោះទេ។ យោងទៅតាមលោក Bauman ពាក្យប្រឆាំងនឹងពួកជ្វីហ្វដែលត្រូវបានបង្កើត និងប្រើជាទូទៅនៅចុងបញ្ចប់នៃសតវត្សរ៍ទី១៩ មិនអាចផ្តល់នូវការពន្យល់ដ៏ស្មុគស្មាញនៃអំពើហឹង្សានេះបានទេ វាខ្វះភស្តុតាងប្រវត្តិសាស្ត្រ ឬសហសម័យ។[4]

ការរើសអើង និងការស្អប់ខ្ពើមមិនអាចពន្យល់ពីអំពើប្រល័យពូជសាសន៍នៅសម័យទំនើបបានទេ។ អារម្មណ៍មិនសមហេតុផល និងព្រៃផ្សៃ មិនមែនជាមូលហេតុចំបង ឬមធ្យោបាយនៃការសម្លាប់រង្គាលនោះទេ។ គោលដៅចុងក្រោយនៃលទ្ធិណាហ្ស៊ីសនិយមគឺពិភពសង្គម និងការកសាងសង្គមនោះឲ្យល្អដ៏ល្អឥតខ្ចោះ។ សង្គមល្អឥតខ្ចោះ ឬការរចនាកសាងនៅក្នុងករណីនេះ វាគឺជាវិនាសកម្មមានអាយុខ្ទង់ពាន់ឆ្នាំ ឬជាអាណាចក្រនៃស្មារតីវិញ្ញាណនៃការរំដោះអាល្លឺម៉ង់។[5] វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការិយាធិបតេយ្យទំនើបត្រូវបានប្រើជាជាងការប្រើអារម្មណ៍ ដោយមិនសមហេតុផល សុទ្ធតែត្រូវបានប្រើប្រាស់ដើម្បីសម្រេចគោលដៅនេះ។[6]

ការគូសវាសលើការវិភាគរបស់Max Weber អំពីការិយាធិបតេយ្យ និងវប្បធម៌សនិទានកម្ម Bauman បានគូសបញ្ជាក់ "សនិទានកម្មការិយាធិបតេយ្យ" នៃវិនាសកម្មឈ្មោះផ្លូវការរបស់នាយកដ្ឋាននៅក្នុងទីស្នាក់ការកណ្តាល ទទួលបន្ទុកលើការបំផ្លិចបំផ្លាញរបស់ជនជាតិជ្វីហ្វនោះគឺ "ផ្នែករដ្ឋបាល និងសេដ្ឋកិច្ច" ។ គំនិតនៃដំណោះស្រាយចុងក្រោយ (Endlösung) គឺជា "លទ្ធផលនៃវប្បធម៌ការិយាធិបតេយ្យ" ។ ពួកណាហ្ស៊ីសបានគិតអំពីការសម្លាប់ជនជាតិជ្វីហ្វនៅពេលដែលពួកគេបរាជ័យក្នុងការស្វែងរក "កន្លែងនារទេសសម្រាប់ជនជាតិជ្វីហ្វ" ដែលរស់នៅក្នុងទ្វីបអឺរ៉ុប មិនថានៅនីស្កូ ម៉ាដាហ្គាស្ការ ឬហួសពីព្រំដែនបន្ទាត់ Archangel-Astrakhan នោះទេ។ Bauman បដិសេធការយល់ឃើញដែលថាវិនាសកម្មHolocaust គឺជា "លំហូរចេញដោយមិនសមហេតុផលពីសំណល់នៃភាពព្រៃផ្សៃកើតមានមុនសម័យថ្មី" ដោយគាត់ប្រកែកថា "វាជាអ្វីដែលមានស្របច្បាប់នៅក្នុងផ្ទះនៃភាពទំនើបពោលគឺក្នុងសម័យទំនើបតែម្តង"។ ដើម្បីគាំទ្រអំណះអំណាងនេះ គាត់សំដៅទៅលើខ្សែការពារដែលត្រូវបានអនុម័តដោយលោកវេជ្ជបណ្ឌិត Servatiusដែលជាទីប្រឹក្សារបស់ Adolf Eichmann នៅក្រុងយេរូសាឡឹម កំឡុងពេលកាត់ក្តីរបស់គាត់ក្នុងឆ្នាំ 1961៖ "Eichmann បានប្រព្រឹត្តិអំពើដែលយកមុខលម្អប្រសិនបើនរណាម្នាក់ឈ្នះ ហើយទៅរកទីតាំងលាក់តាំងលាក់ខ្លួនប្រសិនបើ ម្នាក់នោះចាញ់ពោលជាទង្វើក្បត់មិនស្មោះត្រង់»។ ម្យ៉ាងវិញទៀត សកម្មភាពការិយាធិបតេយ្យ និងសនិទានភាព ឬហេតុផលនិយមនៅក្នុងផែនទីនៃពិភពលោកទំនើប «មិនមានតម្លៃខាងសីលធម៌ខាងក្នុងនោះទេ» និងការវាយតម្លៃសីលធម៌គឺជាអ្វីមួយបើគ្រាន់តែជាផ្នែក «ខាងក្រៅចំពោះសកម្មភាពខ្លួនឯងប៉ុណ្ណោះ»។

វិទ្យាស្ថានវិទ្យាសាស្ត្រក្រោមការដឹកនាំរបស់ណាហ្ស៊ីសត្រូវបានបង្កើតឡើងដើម្បីស៊ើបអង្កេត ធ្វើការសាក់សួរទៅពួកជនជាតិជ្វីហ្វ និងដើម្បីផ្តល់នូវដំណោះស្រាយដែលបានបង្កើតឡើងដោយហេតុផល។ ការលុបបំបាត់ជនជាតិជ្វីហ្វដែលត្រូវបានគេហៅថា Gesundung (ការព្យាបាលជំងឺនៅទ្វីបអឺរ៉ុប) Selbsttreinigung (ការសម្អាតដោយខ្លួនឯង) Judensäuberung (ការសម្អាតជនជាតិជ្វីហ្វ) អនាម័យ prophylactic និង eine Frage der politischen Hygiene (ការសាក់សួរដើម្បីបង្កើតភាពស្អាតស្អំក្នុងនយោបាយ)។ ការសម្លាប់ជនជាតិជ្វីហ្វដូច្នេះត្រូវបានបង្ហាញថាជា "ការអនុវត្តក្នុងការគ្រប់គ្រងសនិទានភាពពោលដោយហេតុផលនិយមនៅក្នុងសង្គម"និង"ការប៉ុនប៉ងជាប្រព័ន្ធដើម្បីដាក់ឱ្យប្រើប្រាស់ក្នុងសេវាកម្មរបស់ខ្លួននូវគោលជំហរ ទស្សនវិជ្ជា និងសិក្ខាបទចំពោះវិទ្យាសាស្ត្រអនុវត្ត។" [8] ទោះជាយ៉ាងនេះក្តី សិទ្ធិអំណាចនៃវិទ្យាសាស្ត្រមិនស្ថិតនៅលើប្រទេសអាល្លឺម៉ង់នោះទេ។ សាកល

វិទ្យាល័យអាល្លឺម៉ង់ តាមទស្សនៈរបស់ Bauman គឺដូចជាសមភាគីរបស់ពួកគេនៅក្នុងប្រទេសទំនើបផ្សេងទៀត ពួកគេទាំងអស់ "បានបណ្ដុះយ៉ាងប្រុងប្រយ័ត្ននូវឧត្តមគតិនៃវិទ្យាសាស្ត្រជាសកម្មភាពដែលមិនមានតម្លៃជាក់ស្តែង។" [9] បានជម្រុះផ្លូវឆ្ពោះទៅរកការប្រល័យពូជសាសន៍តាមរយៈការបំផ្លាញសិទ្ធិអំណាច និងការសោកស្តាយរកពីកម្លាំងទំនាក់ទំនងគ្នាលើទស្សនៈតាមបទដ្ឋានទាំងអស់ ជាពិសេសគឺសាសនា និងសីលធម៌។"[10]

សារៈសំខាន់នៃអំណះអំណាងរបស់ Bauman ស្ថិតនៅក្នុងការពិតដែលថាវាបដិសេធការសន្មត់ថា វិនាសកម្ម ឬHolocaust គឺជាកិច្ចការចំពោះតែសាសន៍ជ្វីហ្វបញ្ហាអាល្លឺម៉ង់នោះគឺ ការបង្កើតរបស់ណាហ្ស៊ីស ឬផលិតផលនៃសង្គមជាតិនិយមជ្រុល ផ្ទុយទៅវិញ វាគឺជាលទ្ធភាពមួយនៃភាពសមហេតុផលនៃភាពទំនើប ដែលអព្យាក្រឹតនយោបាយ និងសីលធម៌។ នៅក្នុងសង្គមវិទ្យាបន្ទាប់ពីការសម្លាប់រង្គាល (1988) ដែលជាកំណែទម្រង់ដំបូងនៃការណែនាំអំពីទំនើបកម្ម និង វិនាសកម្ម (1989) លោក Bauman អះអាងថា ការសម្លាប់រង្គាលគឺជាសកម្មភាពគណនាដោយសមហេតុផលដែលមិនអាចកាត់បន្ថយទៅជាការផ្ទុះដោយតណ្ហាដែលមិនអាចគ្រប់គ្រងបានឡើយ។ ភាពទំនើប តាមទស្សនៈរបស់ Bauman ប្រាថ្នាចង់បានភាពល្អឥតខ្ចោះនៅចុងក្រោយ និងមានស្ថេរភាព ទោះបីជាសេចក្តីប្រាថ្នានេះអាចរួមបញ្ចូលការគាបសង្កត់ ឬអព្យាក្រឹតភាពនៃសកម្មភាពបុគ្គល ក៏ដូចជាការត្រួតត្រាជាសកលលើប្រព័ន្ធ និងសូម្បីអវត្តមានរបស់មនុស្សក៏ដោយ។ វាមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលនោះទេដែលថា Bauman ក៏បដិសេធការបកស្រាយអំពីការសម្លាប់រង្គាលថាជាចំណុចកំពូលនៃការប្រឆាំងនឹងពួកគ្រិស្ទានអឺរ៉ុប ឬជាការរំខានដែលបង្កឡើងនៅក្នុងលំហូរធម្មតានៃប្រវត្តិសាស្ត្រដោយការប្រឆាំងនឹងពួកជ្វីហ្វអាល្លឺម៉ង់ និងពួកណាហ្ស៊ីសនិយម។ ចក្ខុវិស័យមនុស្សធម៌របស់ Bauman ឈានដល់ចំណុចកំពូល នៅពេលដែលគាត់បដិសេធការបំពានរបស់អ៊ីស្រាអែលលើការសម្លាប់រង្គាល និងការចងចាំសោកនាដកម្មរបស់ខ្លួនជាភាពស្របច្បាប់ខាងនយោបាយរបស់អ៊ីស្រាអែល និងជាការបង្ហាញជាមុនសម្រាប់ភាពអយុត្តិធម៌ ដែលខ្លួនអាចប្រព្រឹត្តប្រឆាំងនឹងប៉ាឡេស្ទីន ជាពិសេសនឹងអារ៉ាប់។ វិនាសកម្ម Holocaust តាមទស្សនៈរបស់ Bauman មិនមែនជាលទ្ធផលនៃអារម្មណ៍ Hobbesian ដែលមិនសមហេតុផលនោះទេ ប៉ុន្តែជាផលិតផលនៃអារ្យធម៌ទំនើប និងភាពទំនើបបំផុតតាមបែបវិទ្យាសាស្ត្រ និងជាស្ថាប័នគ្រប់គ្រងដោយវិទ្យាសាស្ត្រដ៏សកម្មបំផុត។ វាជាការពិតដែលហេតុផលឧបករណ៍សម្ភារៈសឹកមិនអាចចាត់ទុកថាជាមូលហេតុចំបងរបស់វិនាសកម្ម Holocaust ប៉ុន្តែវាជាលក្ខខណ្ឌចាំបាច់។[11] ទោះជាយ៉ាងណាក៏ដោយ Bauman ថាការបង្កើតនូវការបំផ្លិចបំផ្លាញ Holocaust មិនថាជាស្ថានភាពធម្មតានៃភាពទំនើប ឬជាពេលដ៏សំខាន់របស់វានោះទេ។ ផ្ទុយទៅវិញគាត់លើកឡើងថាវាជាលទ្ធភាពមួយនៃភាពទំនើប ដែលវាជាបង្អួចឆ្ពោះទៅរកភាពទំនើប និងជាទូទៅមានការសាកល្បងពីភាពទំនើបដែលលោកខាងលិចជៀសវាងក្នុងការប្រឈមមុខ ពោលតែងតែសាកល្បងអាវុធរបស់ពួកគេ។

នៅក្នុងការធ្វើផែនទីពីផលវិបាកនៃភាពទំនើប Elmessiri រិះគន់ប្រព័ន្ធបិទជិតទាំងអស់ដែលចង់គ្រប់គ្រងដោយពេញលេញ និងឥតខ្ចោះទាំងស្រុងៈ លទ្ធិម៉ាក្សនិយម និងការអំពាវនាវរបស់ខ្លួនសម្រាប់សង្គមកុម្មុយនិស្តដែលមិនមានការបង្ហាញណាមួយនៃជម្លោះ និងភាពផ្ទុយគ្នា សេរីនិយម និង

បំណងប្រាថ្នារបស់ខ្លួនក្នុងការប្រើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅក្នុងការបំពេញបំណងប្រាថ្នារបស់មនុស្ស។ លទ្ធិណាហ្ស៊ីសនិយម និងក្តីសុបិន្តរបស់ខ្លួននៃការគ្រប់គ្រងពេញលេញ និងសមហេតុផលឥតខ្ចោះ សណ្តាប់ធ្នាប់ពិភពលោកថ្មី និងមហិច្ឆតារបស់ខ្លួនក្នុងការឈានដល់ច្បាប់ធម្មជាតិជាសកលដែលមិនអើពើនឹងភាពខុសប្លែកគ្នាក្នុងចំណោមវប្បធម៌ ហើយទីបំផុត ស៊ីយូនីស ជ្វីហ្វនិយម និងសកម្មភាពរបស់វា ដូចជា ណាហ្ស៊ីសនិយម, Boden និង Volk ។ នៅទីនេះ ចក្ខុវិស័យ និង praxis របស់ស៊ីយូនីស ជ្វីហ្វនិយម តែងតែត្រូវបានយល់ឃើញនៅក្នុងបរិបទនៃលោកិយនិយមរបស់លកខាងលិច និងពួកចក្រពត្តិនិយម។

ដូចជា Bauman ដែរ Elmessiri បានផ្តោតលើការសម្លាប់រង្គាលជា "គ្រាដ៏អាក្រក់បំផុត" នៃលោកិយនិយមដោយផ្អែកលើហេតុផលដ៏រឹងមាំ ដែលបណ្តាលឱ្យមានស្ថានភាពវិនាសកម្មមនុស្សជាសកលដែលអាចយល់បាននៅក្នុងពាក្យប្រៀបធៀបរបស់ Elmessiri នៃ "ក្រុមមូលដ្ឋាន" ។ ពាក្យប្រៀបធៀបនេះគឺជិតស្និទ្ធទៅនឹងពាក្យប្រៀបធៀបរបស់ Bauman អំពីភាពចម្លែក និងភាពច្របូកច្របល់របស់សង្គមសម័យទំនើប។ Elmessiri សំដៅទៅលើឥស្សរជនលោកខាងលិចសំខាន់ៗ និងឥទ្ធិពលរបស់ពួកគេលើការយល់ដឹងរបស់គាត់អំពីតួនាទីនៃក្រុមមូលដ្ឋានរបស់វា។ នៅក្នុងចំណោមពួកគេមាន Georg Simmel, Karl Marx, Max Weber និង Werner Sombart។[12] ទោះបីជាយ៉ាងណាក៏ដោយ Elmessiri បានរិះគន់ការសិក្សារបស់លោកខាងលិចចំពោះការបរាជ័យរបស់ខ្លួនក្នុងការបញ្ចូលពាក្យប្រៀបធៀបចម្លែកៗទៅក្នុងគំរូនៃការបកស្រាយដ៏ទូលំទូលាយជាងនេះ។ ការជំនួសពាក្យប្រៀបធៀបចម្លែកៗជាមួយនឹងពាក្យប្រៀបធៀបនៃ "ក្រុមមូលដ្ឋាន ឬមុខងា" Elmessiri ព្យាយាមណែនាំគំរូដ៏ទូលំទូលាយមួយដែលអាចគ្របដណ្តប់មនុស្សយ៉ាងធំធេងដែលត្រូវបាននាំចូលពីសង្គមខាងក្រៅ ឬជ្រើសរើសពីក្នុងជួររបស់ខ្លួន និងដែលជាទូទៅត្រូវបានកំណត់នៅក្នុងពាក្យនៃមុខងារច្បាស់លាស់ ជាជាងភាពស្មុគស្មាញនៅក្នុងសង្គមរបស់មនុស្ស។

ដូចដែល Bauman បានបង្ហាញ អ្នកគាំទ្រនៃសង្គមនិយមបានកំណត់ភាពទំនើបជា "ច្បាប់នៃតម្លៃសេដ្ឋកិច្ច និងរូបិយវត្ថុ" ហើយពួកគេបានសន្មត់ថាលក្ខណៈពូជសាសន៍របស់ជនជាតិជ្វីហ្វគឺជាហេតុផលចម្បងដែលនៅពីក្រោយការបាត់បង់នៃ "របៀបរស់នៅ និងស្តង់ដារនៃតម្លៃរបស់មនុស្ស" ។ [13]វាច្បាស់ណាស់សម្រាប់ហេតុផលនេះ ដែលពួកគេត្រូវបានចាត់ទុកថាជា leeches និងបិសាចជញ្ជក់ឈាមពីអ្នកដទៃ ហេតុដូច្នេះហើយ ពួកគេសមនឹងទទួលការស្លាប់ដោយគ្មានការប្រោសនោះឡើយ។ ការហួសចិត្តដ៏ក្រៀមក្រំបំផុត យោងតាមលោក Elmessiri គឺថាការនាំជនជាតិថ្វីហ្វទៅជាជនរងគ្រោះអចិន្ត្រៃយ៍ ឬជាប៉ារ៉ាស៊ីតជាអចិន្ត្រៃយ៍នៅក្នុងសុន្ទរកថាឬគោលការណ៍របស់ Zionist ត្រូវបានប្រឆាំងនូវភាពស្មើគ្នា និងសូម្បីតែភាពអយុត្តិធម៌ក៏គ្មានសម្រាប់ជាតិសាសន៍ដទៃប្រៀបដូជាជា "ចចកជាអចិន្ត្រៃយ៍"ពោលសម្រាប់លទ្ធិជ្វីហ្វនិយមស៊ីយូនីស។[14]

## ជំពូកទី៥
## Bauman និងវិបត្តិនៅសម័យទំនើប

ពាក្យសម័យទំនើប តាមទស្សនៈរបស់ Bauman គូសបញ្ជាក់ពីនិយមន័យ លក្ខណៈនៃលក្ខខណ្ឌដែលបានលេចឡើង នៅទូទាំងបណ្តាប្រទេសអ្នកមាននៅក្នុងដំណើរប្រព្រឹត្តិទៅនៅសតវត្សរ៍ទី២០

និងបានយកហាតុការណ៍បច្ចុប្បន្នរបស់វានៅក្នុងពាក់កណ្តាលទី២នៃសតវត្សរ៍ទី២០នោះ។[1] ចំពោះ Bauman ទោះបីជាយ៉ាងណាក៏ដោយចុះគាត់បានបោះបង់ចោលពាក្យក្រោយសម័យទំនើបទាំងស្រុង ដោយជ្រើសរើសយកពាក្យថ្មីនេះជំនួសវិញ នោះគឺ "ភាពទំនើបនៃអង្គធាតុរាវ"។

"ភាពទំនើបនៃអង្គធាតុរាវ" គឺជាពាក្យប្រៀបធៀបថ្មីដែល Bauman ណែនាំដល់ផែនទីការផ្លាស់ប្តូរនៃសម័យទំនើបរបស់លោកខាងលិច។ នៅក្នុងជីវិតប្រៀបដូចជាអង្គធាតុរាវ Bauman កំណត់របៀបបច្ចុប្បន្ននៃភាពក្លាយជា "ជីវិតនៃអង្គធាតុរាវ" វាគ្របដណ្តប់ដោយបរិយាកាសរីកចម្រើននៃ "ភាពមិនប្រាកដប្រជា" និង "ព្រឹត្តិការណ៍ដែលមានចលនាលឿន" ដែលជា "ការជោគជ័យនៃការចាប់ផ្តើមថ្មី" ឬ "ការបញ្ចប់ដ៏ឆាប់រហ័ស និងគ្មានការឈឺចាប់។" របៀបប្រៀបដូចជាអង្គធាតុរាវនេះត្រូវបានប្រៀបធៀបទៅនឹងល្បែងប្រថុយប្រថាន និងគួរឱ្យភ័យខ្លាច ដែលគំរាមកំហែងដកអ្នកគ្មានអំណាច អ្នកក្រ និងអស់អ្នកដែលមិនអាច ឬមិនចង់ទប់ទល់នឹងជីវិតដូចជាវត្ថុធាតុរាវដែលផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ វឌ្ឍនភាពមិនមែនជាពាក្យប្រៀបធៀបនៃ "ក្តីសុបិនដ៏ផ្អែមល្ហែម និងការរំពឹងទុក" "សុទិដ្ឋិនិយមជ្រុល" និង "ការសន្យានៃសុភមង្គលរួម និងយូរអង្វែង" ប៉ុន្តែជាសុបិន្តអាក្រក់ដ៏គួរឱ្យភ័យខ្លាច និង "ល្បែងលេងប្រៀបដូចជាកៅអីនៃកម្មវិធីតន្ត្រី" ដ៏អាក្រក់បំផុត ដែលការមិនចាប់អារម្មណ៍របស់វិនាទីនាំឱ្យមានលទ្ធផលការបរាជ័យដែលមិនអាចវិលត្រឡប់វិញបាន និងការដកខ្លួនចេញ។[3]

មិនដូចភាពទំនើបដែលរឹងមាំនោះទេ ភាពទំនើបប្រៀបដូចជាអង្គធាតុរាវនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹង "រជ្ជកាលសេរីនៃគោលការណ៍រីករាយនៅក្នុងអាណាចក្រនៃការប្រើប្រាស់" ពីព្រោះការពិតមិនមែនជាសត្រូវនៃការសប្បាយទៀតទេ។ ផ្ទុយទៅវិញ "ការចំណាយគឺជាកាតព្វកិច្ច" ព្រោះវាផ្តល់ឱ្យ "ការប្រជែងគ្នាជានិមិត្តរូប" និងផ្តាច់មុខ "និយមន័យនៃជីវិតល្អ"។[4] នៅទីនេះ និក្ខេបបទរបស់ Bauman ត្រូវបានកំណត់ផ្ទុយស្រឡះជាមួយនឹងការទួញសោកចាស់របស់Freud ព្រោះគោលការណ៍ការពិត «ថ្ងៃនេះត្រូវការពារខ្លួនក្នុងតុលាការយុត្តិធម៌ដែលគោលការណ៍រីករាយជាគោលការណ៍ធំសម្រាប់ចៅក្រម»។

នៅក្នុងយុគសម័យទំនើបប្រៀបដូចជាអង្គធាតុរាវនេះ ផែនទីការយល់ដឹងរបស់អ្នកប្រើប្រាស់នាពេលអនាគតត្រូវបានរៀបចំដោយនិមិត្តសញ្ញាដែលទាក់ទាញ៖ (1) សិទ្ធិអំណាចរបស់តារាល្បី (បុគ្គលិកមានលក្ខណៈសាធារណៈ អត្តពលិកដ៏អស្ចារ្យ តារាសម្តែង និងអ្នកចម្រៀងដ៏ពេញនិយម) និង (2) សិទ្ធិអំណាចនៃវិទ្យាសាស្ត្រ (សិទ្ធិអំណាចនៃវិទ្យាសាស្ត្រ ការស្ទង់មតិ លេខ និងរូបមន្តពិជគណិត)។ អ្វីទាំងនេះគឺជា "និមិត្តសញ្ញានៃការយល់ព្រមពីសង្គម" "ចំណេះដឹងសមហេតុផល និងរឹងមាំ" និង "ជម្រើសដែលមានព័ត៌មានល្អ។"[6] Bauman ផ្តល់យោបល់ថាភាពទំនើបដូចជាអង្គធាតុរាវអាចត្រូវបានគេមើលឃើញថាជា "វប្បធម៌ដូចល្បែងនៅកាស៊ីណូ" ដែលជីវិតត្រូវបានប្រែក្លាយទៅជាហ្គេមបុគ្គលនៃវគ្គ "ការបិទបាំងដោយខ្លួនឯង យោងដោយខ្លួនឯង និងវគ្គដែលផ្តោតលើខ្លួនឯង" ដែលជា "សេរីភាពនៃការចាប់ផ្តើមថ្មី" ឬដូចជា "ការប្រមូលរឿងខ្លីៗ" [7] គួរឱ្យស្តាយបំផុត យោងទៅតាមលោក Bauman គឺថាការប្រើប្រាស់ដែលខ្ជះខ្ជាយក្លាយជាសញ្ញានៃភាពជោគជ័យ និងកិត្តិនាម។ ការគ្រប់គ្រង និងប្រើប្រាស់វត្ថុមួយចំនួនត្រូវបានគេមើលឃើញថាជាលក្ខខណ្ឌចាំបាច់នៃសុភមង្គល និងប្រហែលជាសូម្បីតែសេចក្តីថ្លៃថ្នូររបស់មនុស្ស។[8]

ដូចដែល Bauman ណែនាំនៅក្នុងក្រដាសសរសេររបស់គាត់ដោយបំផុសគំនិតអំពី "On Postmodern Uses of Sex សកម្មភាពផ្លូវភេទនៅក្នុងការបង្ហាញនៅសម័យទំនើបរបស់វាត្រូវបាន "ផ្តោតយ៉ាងតូចចង្អៀតលើឥទ្ធិពលដល់ចំណុចកំពូលរបស់វា... ភារកិច្ចសំខាន់របស់វាគឺដើម្បីផ្គត់ផ្គង់ឱ្យកាន់តែរឹងមាំ ការប្រែប្រួលមិនចេះចប់ ដូចជាប្រលោមលោកឥតខ្ចោះ និង Erlebnisse ដែលមិនធ្លាប់មានពីមុនមក។[9] ការអំណរនៃការរួមមេត្រីត្រូវបានអមដោយភាពមិនត្រឹមតែជាមួយនឹងភាពស្និទ្ធស្នាលរបស់គ្រួសារដែលជាសមាសភាពសង្គម ជាមូលដ្ឋាន ប៉ុន្តែក៏មានហានិភ័យថ្មីនៃសេចក្តីស្រឡាញ់របស់ឪពុក និងភាពស្និទ្ធស្នាលផងដែរ។[10] អ្នកទេសចរ និងមនុស្សល្ងីល្ងើត្រូវបានតំណាងថាជា "ពាក្យប្រៀបធៀបនៃជីវិតសម័យថ្មី" ដ៏សំខាន់ពីព្រោះយើងទាំងអស់គ្នាត្រូវបានគ្រោងទុកនៅលើការបន្តដែលលាតសន្ធឹងរវាងចំណុចនៃ "អ្នកទេសចរដែលល្អឥតខ្ចោះ" និង "ភាពច្របូកច្របល់ហួសហេតុរបស់សង្គម"។[11]

# ជំពូកទី៦
# Elmessiri និងសម័យទំនើបដែលប្រៀបដូចជាអង្គធាតុរាវ

មិនដូច Baumanដែលការរិះគន់លើនៃភាពទំនើបបានរំពឹងទុកមុនរបស់គាត់។ ព្រឹត្តិការណ៍ដែលកើតឡើងនៅសម័យទំនើប Elmessiri មិនដែលឃើញភាពក្រោយសម័យទំនើបនេះជាការរំដោះខ្លួនពហុនិយម ឬការអត់ឱននៃភាពខុសគ្នានោះឡើយ។ ផ្ទុយទៅវិញ លោកបានចាត់ទុកវាថាជាប្រភេទ nihilistic ពោលគឺជំនឿមួយថាជីវិតគឺគ្មានន័យ និងទំនាក់ទំនង ដែលជាទស្សនវិជ្ជារួមជាមួយនឹងអារម្មណ៍ស្អុតស្អាញខ្លាំង ចំពោះការអនុវត្តជាក់ស្តែង។ មិនដូច Baumanដែលមានការរំពឹងទុកពីភាពដ៏អស្ចារ្យ និងរំពឹងខ្ពស់ពីសម័យក្រោយនៃសម័យទំនើប Elmessiri ទទូចតាំងពីដើមដំបូងថានៅសម័យទំនើបពិភពលោកថា គ្មានអ្វីក្រៅពីសម្ភារៈនិយមសុទ្ធសាធ នៅក្នុងលំហូរជារៀងរហូតដោយគ្មានប្រភពដើម ឬគោលបំណងនោះឡើយ។ មិនដូច Baumanដែលនៅតែស្មោះត្រង់នឹងគម្រោងលើភាពទំនើប និងមានការរំពឹងទុកដ៏អស្ចារ្យក្នុងការសម្រេចបានតាមរយៈភាពទាន់សម័យនោះ លោក Elmessirវិញ មិនដែលបោះបង់ចោលការសន្មតជាមូលដ្ឋានរបស់គាត់ដែលថាក្រោយសម័យទំនើបគឺស្ទើរតែមានន័យដូចគ្នាជាមួយនឹងភាពបរាជ័យនៃភាពទំនើបនិងភាពក្ស័យធនរបស់វា។[1]

នៅក្នុងដំណាក់កាលនៃសម្ភារៈនិយមដោយមិនសមហេតុផល មនុស្សស្ទើរតែទាំងអស់ត្រូវបានប្រែក្លាយទៅជាក្រុមសភាវៈ ឬ Mamluks ។ យើងអាចនិយាយបានថាលក្ខខណ្ឌនៅសម័យទំនើបគឺជាលក្ខខណ្ឌនៃការខ្ចីឃ្លារបស់ Ernest Gellner ដែលជា Mamluk ជាសកល ឬខ្ចីពី Elmessiri ដែលមានន័យថាជាក្រុមនៃមុខងារ។ ក្រោយមកទៀតគឺជាក្រមនៃយុគសម័យនៃលទ្ធិលោកិយនិយមដ៏ទូលំទូលាយ និងវារួមបញ្ចូលនៅក្នុងទស្សនៈរបស់ Elmessiri ជនអន្តោប្រវេសន៍ទាំងនៅបស្ចិមប្រទេស និងប្រទេសឈូងសមុទ្រ កម្មករក្នុងឧស្សាហកម្មនៃភាពសប្បាយ មានដូចជា (ស្រីពេស្យា ពិធីការិនី តារាភាពយន្ត បុរស និងស្ត្រីនក្នុងវិស័យកីឡា តារាម៉ូដែល និងតារាក្នុងភាពយន្តពេស្យា) ភ្ញៀវទេសចរ ឥស្សរជនយោធា ឥស្សរជនវិស័យវប្បធម៌ និងនយោបាយ និងសូម្បីតែមន្ត្រីមុខងាររដ្ឋ ឬភ្នាក់ងារជាទូទៅរបស់រដ្ឋក៏ដោយ។[2]

ដូចជា Bauman ដែលបានតាមដានភាពលេចធ្លោនៃការរួមភេទពេលសម្រាប់មនុស្សសម័យថ្មី ជាពាក្យប្រៀបធៀបដ៏សំខាន់មួយនៃភាពទំនើបនៃសង្គមសម័យទំនើប លោក Elmessiri យល់ថា ការកើនឡើងនៃកម្រិតនៃសនិទានភាវូបនីយកម្ម និងភាពមិនស្ថិតស្ថេរបាននាំទៅដល់ការលេចចេញ និងការអភិវឌ្ឍនៃរូបរាងថ្មី៖"រូបកាយរបស់មនុស្សគឺជាពាក្យប្រៀបធៀបជាមូលដ្ឋាននៅក្នុងយុគសម័យនៃទំនើបកម្ម។ ឥឡូវនេះ សិចពេលគឺសកម្មភាពរួមមេត្រីមុនរៀបការរបស់មនុស្សសម័យទំនើបបានក្លាយជាពាក្យប្រៀបធៀបដ៏សំខាន់បង្ហាញពីស្ថានភាពសង្គមនៅសម័យទំនើប»[3] Elmessiri ថែមទាំងប្រកែកថាទស្សនវិជ្ជាលោកខាងលិចសម័យទំនើបផ្តល់តម្លៃឱ្យការរួមភេទជា "ភាពសំខាន់ខាងដួងស្មារតីលើអ្វីៗទាំងអស់។"[4] ភាពសំខាន់នេះអាចត្រូវបានកំណត់គុណលក្ខណៈដោយការខិតខំដកខ្លួនចេញពីពិភពដ៏ស្មុគស្មាញនៃគុណតម្លៃ សីលធម៌ កាតព្វកិច្ច និងទំនួលខុសត្រូវ។[5]

សកម្មភាពនៃការរួមភេទក៏ត្រូវបានអមជាមួយនឹងភាពមិនច្បាស់នៃទំនាក់ទំនងគ្រួសារ និងការកើតឡើងនៃសញ្ញានៃភាពមិនច្បាស់លាស់ថ្មី។ ជាមួយនឹងសកម្មភាពនៃការរួមភេទដែលហាក់ដូចជារឿងធម្មតា ឬអ្វីដែល Elmessiri លើកឡើងដែលថា ជាធម្មតាសំដៅថាវាជា "ការរួមភេទភ្លាមៗ" វាគឺជាការរួមភេទ និងតម្លៃរបស់ត្រូវបានបំបែកយ៉ាងច្បាស់ពេលពីតម្លៃនៃសីលធមសង្គម និងកាត់បន្ថយវាទៅជាត្រឹមតែជាទំនាក់ទំនងរាងកាយដែលមានលក្ខណៈបណ្តោះអាសន្នពេលរវាងបុរស និងស្ត្រី ដែលមានបំណងចង់ឱ្យមានការពេញចិត្តសប្បាយភ្លាមៗប៉ុណ្ណោះ។ មិនគួរឱ្យភ្ញាក់ផ្អើលទេ ពេស្យាចារជាឧទាហរណ៍ចាត់ទុកគ្រាន់តែជា "សកម្មភាពសេដ្ឋកិច្ច" ហើយពាក្យភាសា "ស្រីពេស្យា" ត្រូវបានផ្លាស់ប្តូរទៅជា "អ្នករកស៊ីផ្លូវភេទ" ដែលជាពាក្យថ្មីដែលតំណាងឱ្យស្ត្រីពេស្យា បំពេញការងារជាកម្មករ និងកម្លាំងសេដ្ឋកិច្ចនៅក្នុងសង្គមទៅវិញ។ [6]

ដំណើរការនៃភាពមិនច្បាស់លាស់ដូចគ្នានេះ បើយោងតាម Elmessiri អាចត្រូវបានគេមើលឃើញនៅក្នុងការផ្លាស់ប្តូរនៃពាក្យ និងអ្វីដែលបានមើលឃើញផ្សេងទៀតដូចជា "កូនខុសច្បាប់" ដែលបានក្លាយជា "កូនរបស់ម្តាយដែលមិនទាន់រៀបការ" "កូននៃគ្រួសារដែលមានអាណាព្យាបាលតែម្នាក់គត់" "កូនឥតខាន់ស្លា ″ "កូនចេញពីធម្មជាតិពេលរវាងប្រុសស្រី" និង "កូនកើតចេញតណ្ហានៃក្តីស្រឡាញ់ប្រុសស្រីពេលមិនទាន់រៀបការ"។ និយាយឱ្យខ្លីពួកគេគឺជាកូនចេញពីធម្មជាតិពេលរវាងប្រុសស្រី។ Elmessiri ប្រកែកថា ការរួមភេទនៅសម័យទំនើប ឬដើម្បីឱ្យកាន់តែច្បាស់លាស់ វាក៏ដូចជាការលុបបំបាត់ភាពបរិសុទ្ធពេលតម្លៃនៃការរួមភេទបង្កើតកូនចៅដោយការរៀបការ បានធ្វើឱ្យបុរសក្លាយជា "មនុស្សង្កើតនូវបញ្ហាស្មុគស្មាញ" ដល់សង្គមពេលជា( ឪពុក/ម្តាយ ប្តី/ប្រពន្ធ ប្រុស/ស្រី )។ នៅក្នុងសម្លេងដ៏ហួសចិត្ត ប៉ុន្តែធ្ងន់ Elmessir ប្រកែកថា "ការវិវត្តតាមធម្មជាតិ" នៃការស្រើបស្រាលលើការរួមភេទបង្ហាញពីការព្រងើយកន្តើយចំពោះបម្រាមនៃការរួមរ័ក្ស ការស្រឡាញ់ភេទដូចគ្នា និងការប្រារព្ធពិធីzoophilia។[7]

ការចាប់អារម្មណ៍លើ (ទស្សនវិជ្ជា កត្តិបណ្ឌិតសេចក្តីស្រឡាញ់) ឥឡូវនេះត្រូវបានជំនួសដោយការចាប់អារម្មណ៍លើអំពើអនាចារ និងដូចជាសត្វពាហនៈ។[8] អ្វីដែលគួរឱ្យសោកស្តាយបំផុតនោះគឺថា ភាពមិនធម្មតានៃផ្លូវភេទ ដែលជាការរំលោភលើធម្មជាតិរបស់មនុស្ស ត្រូវបានការពារក្នុងនាមសិទ្ធិមនុស្សទៅវិញ។ មនុស្សត្រូវបានកាត់មកជាត្រឹមតែសាច់ឈាម ពេលឬជាឧបករណ៍ ដើម្បីយកមក

 ប្រើប្រាស់ជាប្រភពនៃការសប្បាយត្រេកត្រអាលពលលសម្រាប់តណ្ហាទៅវិញ។[9]

យោងតាមលោក Elmessiri មនុស្សនៅសម័យទំនើបប្រាថ្នាចង់បង្កើតពិភពលោកដោយគ្មានឯកសារយោងណាមួយចំពោះសញ្ញាណនៃអត្តសញ្ញាណ ការចងចាំ ប្រវត្តិសាស្ត្រ ពេលវេលា និមិត្តសញ្ញា ប្រភពដើម សេចក្តីពិត និងភាពបរិសុទ្ធ វិចារណកថា ពោលគឺពិភពលោកដែលបង្កើតឡើងដើម្បីតែអំណាច ការលេងសើចដោយសេរី តណ្ហា និងការសប្បាយ។ នៅក្នុងការវិភាគរបស់គាត់អំពីការប្រារព្ធពិធីបុណ្យសពនៅក្នុងសង្គមសម័យទំនើប។ Elmessiri សំដៅលើជំនឿរបស់ Bauman ដែលថាអវត្តមាននៃប្រធានបទដ៏វិសេសវិសាលលើទេវភាព ឬមនុស្ស។ វាមានន័យថា រដ្ឋកាលនៃភាពមិនសមហេតុសមផល និងថាអវត្តមាននៃភាពពេញលេញខាងសាសនាបានដឹកនាំសង្គមមនុស្ស តាមទស្សនៈរបស់ Bauman រហូតដល់ការប្រារព្ធពិធីបុណ្យសព ពោលដោយវាធ្វើឡើងដោយមិនទំនងមិនសមហេតុផល។ នៅពេលដែលរូបកាយរបស់មនុស្សក្លាយជាសព ចំណុចចុងក្រោយរបស់ពួកគេគឺ គំនិតនៃសហគមន៍ សង្គម និងអត្តសញ្ញាណសមូហភាព ដែលសន្ធត់ទៅលើមនុស្ស ឬសពនោះ ថាវាលែងមានន័យ ឬមានតម្លៃទៀតឡើយ។[10]

Elmessiri រៀបរាប់អំពីឧទាហរណ៍ដែលបង្ហាញពីចំណុចកណ្តាលនៃការរួមភេទនៅក្នុងទិដ្ឋភាពពិភពលោកនៅសម័យទំនើប៖ ការពិពណ៌នារបស់ Derrida អំពីការបំផ្លាញថាវាជា "ការឈានដល់ចំណុចកំពូលជាបន្តបន្ទាប់" "ការរីករាយនៃអត្ថបទ" របស់ Barthes ជាទង្វើនៃការពេញចិត្តខាងផ្លូវភេទ ការអំពាវនាវឱ្យមានសកម្មភាពបំពានជា (និមិត្តសញ្ញាមួយនៃភាពមិនស្ថិតស្ថេរ) ជំនួសឱ្យការស្រមើស្រមៃ (ជានិមិត្តរូបនៃវិសាលភាព) និងការរួមផ្សំនៃលទ្ធិlogocentrism ចូលទៅក្នុងលទ្ធិ phallogocentrism, សោភ័ណភាពនិងការយល់ដឹងរបស់វាចូលទៅក្នុងអារម្មណ៍ពី អត្ថបទពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទ សៀវភៅអំពីការរួមភេទ ដូចជាeschatology នៅក្នុង scatologyជាដើម ពោលទាំងអស់នោះសុទ្ធតែបំផ្លាញគុណតម្លៃមនុស្សជាតិ។[11]

ការរួមភេទក្លាយជា 'ការជំនួសសម្រាប់ពាក្យនៃភាសា' ដែលផ្តើននឹងការបកស្រាយ ព្រោះវាក្លាយជាចំណុចពិតមានជាក់ស្តែងខ្លឹមសារនៃឯកសារយោងនានាចំអកដល់បញ្ហាដែលកើតមានឡើង។ ដូចដែលElmessiri ណែនាំ អំពីសង្គមសម័យទំនើបឥឡូវនេះទាក់ទងនឹងសោភ័ណភាពទៅនឹងអារម្មណ៍មនោសញ្ចេតនានិង intertextualityទាក់ទងទៅនឹងបញ្ហារឿងផ្លូវភេទសម្រាប់សង្គម។[12]

Elmessiri មានការយល់ដឹងយ៉ាងខ្លាំងអំពីកម្មវត្ថុ និងមនោគមវិជ្ជារបស់គាត់ ដូច្នេះហើយគាត់មិនដែលច្រឡំពីជាតិសាសន៍ជ្វីហ្វ សាសនាយូដា និងចលនាជ្វីហ្វនិយមដែលជាស៊ីយូនីសនោះឡើយ។ ទាំងអស់ និងខាងលើ គាត់បានបដិសេធទ្រឹស្តីសមគំនិតដែលបង្ហាញថានៅសម័យទំនើប លទ្ធផល ឬការកសាងឡើងវិញគឺជានិន្នាការរបស់ជនជាតិជ្វីហ្វ ដែលសំដៅទៅលើការរលាយនៃអ្វីៗដែលមិនច្បាស់លាស់ទាំងអស់។ Elmessiri សន្មត់ថាជាជំនឿទូទៅដែលខុសឆ្គងក្នុងចំណោមអ្នកប្រាជ្ញលោកខាងលិចចំពោះបទពិសោធន៍ប្រវត្តិសាស្ត្ររបស់ជនជាតិជ្វីហ្វជាអ្នកដែលភៀសខ្លួន (pariah Volk) និងការគូសផែនទីការយល់ដឹងរបស់ជនជាតិជ្វីហ្វ ថាគឺជាអ្នករស់នៅ ពោលគឺអ្នកវង្វេងអស់កល្បជានិច្ចដែលសុបិនអំពីទឹកដីនៃការសន្យារបស់ពួកគេ។ ដូច្នេះជនជាតិជ្វីហ្វត្រូវបានតំណាងថាជាសញ្ញា

ដែលបំបែកចេញពីសញ្ញាញ ឬសញ្ញាដែលមានអត្ថន័យលើស និងគ្មានកំណត់។ ចំណាប់អារម្មណ៍របស់ Elmessiri លើសារៈសំខាន់របស់ជនជាតិជ្វីហ្វក្នុងការបកស្រាយនៅក្នុងសម័យទំនើបមិនអាចត្រូវបានកំណត់នូវគុណលក្ខណៈត្រឹមតែភាពលំអៀងខាងវប្បធម៌របស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាគំរូលេចធ្លោដែលទទួលយកស្ថានភាពវត្តមានរបស់ជនជាតិជ្វីហ្វមុន និងក្រោយសង្គ្រាមលោកលើកទី២ ដែលជាការបង្ហាញអំពីផលវិបាកទាំងនៅមុនសម័យទំនើប និងសម័យទំនើប។ ដូចដែល Max Silverman បានបង្ហាញ ការចោទប្រកាន់ក្រោយការសម្លាប់រង្គាលរបស់ជនជាតិជ្វីហ្វមានសារៈសំខាន់ខ្លាំងណាស់ក្នុងការចូលទៅជិតសំណួរកាន់តែទូលំទូលាយអំពីមុនសម័យទំនើប និងសម័យទំនើបនោះឯង។[13]

ទោះបីយ៉ាងណាក៏ដោយ Elmessiri បដិសេធការសន្មតថាជនជាតិជ្វីហ្វអាចជាត្រូវបានមើលឃើញថាជាអ្នកផ្សព្វផ្សាយនៃគោលលទ្ធិនៃសម័យទំនើប( nihilism, deconstruction, fragmentation )។ ជំនឿទូទៅនេះបើយោងតាមលោក Elmessiri បង្ហាញពីមនោគមវិជ្ជាប្រកាន់ពូជសាសន៍ នៅពេលដែលវាបានធ្វើជនជាតិជ្វីហ្វទៅជាកម្លាំងដ៏គួរឱ្យភ័យខ្លាច និងអាក្រក់នៅក្នុងសេចក្តីងងឹត។[14]

Elmessiri មិនភ្ញាក់ផ្អើលចំពោះភាពឃោឃៅរបស់សាសន៍ជ្វីហ្វបែបនេះទេ និងគាត់បញ្ជាក់ថា វាស្របនឹងឃ្លាំងអាវុធរបស់លោកខាងលិចដែលមាននិន្នាការប្រកាន់ពូជសាសន៍។ ជំនួសឱ្យការមើលជនជាតិជ្វីហ្វថាជាមនុស្សធម្មតាដែលមានទាំងល្អ និងអាក្រក់។ លោកខាងលិចគិតថាវាតំណាងឱ្យជនជាតិជ្វីហ្វទាំងអស់ជានិមិត្តសញ្ញានៃមុខងារជាតិសាសន៍និយមជ្រុល ឬnihilism ។ ការសរសេរប្រវត្តិសាស្ត្រនៃសហគមន៍ជ្វីហ្វត្រូវបានកំណត់លក្ខណៈតាមទស្សនៈរបស់ Elmessiri ដោយភាពជាក់ស្តែងពីរ ព្រោះវាបង្ហាញពួកគេជាសរុបតែម្តង ពោលគឺជា "ជនជាតិជ្វីហ្វ" ឬជា "ជនជាតិជ្វីហ្វដែលបានជ្រើសរើស" មិនមែនជាជនជាតិភាគតិចដែលមានវប្បធម៌ខុសៗគ្នា និងផ្ទៃខាងក្រោយនៃសង្គមពោលផ្សេងៗគ្នានោះឡើយ។ សំខាន់ជាងនេះទៅទៀត សហគមន៍ជ្វីហ្វត្រូវបានបង្ហាញដោយចៃដន្យ ជាក្រុមមានមុខងារ ពោលគឺជាពាណិជ្ជករ នាយទុនអ្នកឱ្យគេខ្ចីលុយ និងធនធានមនុស្ស ឬ Elmessiri ថាជា "បញ្ហានៃការប្រើប្រាស់របស់មនុស្ស" ដែលវាអាចត្រូវបានពាក់ព័ន្ធទៅនឹងការបម្រើផលប្រយោជន៍សម្រាប់អ្នកដទៃ។[15]

ដូច Bauman ដែរ Elmessiri ប្រកែកអះអាងថាលោកខាងលិចបានបង្កើតពិភពលោកជា "កន្លែងទុកទំនេរ" ដែលជា"ឧបករណ៍សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន" ដែលជាកន្លែងដ៏ព្រៃផ្សៃ ចន្លោះទទេរនោះ រង់ចាំបេសកកម្មដ៏ស៊ីវិល័យរបស់ពួកគេ។ មិនដូចBauman ទោះបីជាយ៉ាងណាក៏ដោយ Elmessiri តែងតែប្រកែកអះអាងថា Zionismចលនាជ្វីហ្វនិយម គឺជាកូនចៅនៃកេរដំណែលចក្រពត្តិអឺរ៉ុប។ ដោយបដិសេធពីប្រវត្តិសាស្ត្រអារ៉ាប់ និងអ៊ីស្លាម ក្រុមស៊ីយ៉ូនីសជ្វីហ្វនិយមយល់ឃើញប៉ាឡេស្ទីនថាជា ទឹកដីគ្មានមនុស្ស ជាលំហភូមិសាស្ត្រគ្មានប្រវត្តិសាស្ត្រ និងកន្លែងទំនេរដែលរស់នៅដោយមនុស្សដែលខ្ចាត់ខ្ចាយ និងបែងចែកគ្នា។ Elmessiri អះអាងថាអ្វីដែលជារឿងធម្មតារវាងសម័យទំនើប និងចោនាZionism ជ្វីហ្វនិយម គឺជាការប៉ុនប៉ងដ៏ក្តៅគគុកដើម្បីបំបែកសញ្ញាសម្គាល់ពីសញ្ញាញដើម្បីឱ្យអត្តសញ្ញាណរបស់ទាំងជនជាតិជ្វីហ្វ និងអារ៉ាប់អាចត្រូវបានរំលាយបានយ៉ាងងាយស្រួលដោយកាត់បន្ថយទៅជាសញ្ញាណដែលគ្មានឫសគល់ ដែលអាចផ្ទេរបានយ៉ាងងាយស្រួលទៅកន្លែង

ផ្សេង និងទឹកដីថ្មីដែលត្រូវផ្តល់ឲ្យជាមួយនឹងអត្តសញ្ញាណថ្មី។ វាមិនគួរឱ្យភ្ញាក់ផ្អើលទេដែលជនជាតិជ្វីហ្វក្លាយជាអ្នកតាំងលំនៅដោយចលនា Zionistជ្វីហ្វ ពេលអ្វីដែលកើតមានដូចជា ជនភៀសខ្លួនប៉ាឡេស្ទីនអារ៉ាប់ ប៉ាឡេស្ទីនអ៊ីស្រាអែល អ្វីដែលកើតមាននៅតំបន់ West Bank (al-Difa al-Gharbiyya) Judea និង Samaria និងបញ្ហាពិភពអារ៉ាប់ ទីផ្សារនៅមជ្ឈិមបូព៌ា រួមមានបញ្ហា "ផ្ទៃទឹកទួរគី" "រដ្ឋធានីនៃប្រទេសឈូងសមុទ្រអារ៉ាប់" "បញ្ហាកម្លាំងពលកម្មពលរដ្ឋអេហ្ស៊ីប"និង «ចំណេះដឹងរបស់ជនជាតិអ៊ីស្រាអែល» ពេលដែលរីកចម្រើន សុទ្ធតែជាផែនការគ្រោងរបស់ចលនាជ្វីហ្វនិយម Zionisទាំងអស់។ [16]

គោលគំនិតនៃតំបន់នេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះជាធម្មតាវាត្រូវបានគេប្រើដើម្បីសំដៅទៅលើមជ្ឈិមបូព៌ា។ វាតំណាងឱ្យការពិតពភូមិសាស្រ្តសុទ្ធសាធ ដោយគ្មានយោងទៅលើប្រវត្តិសាស្រ្តភាសា និងសាសនានោះឡើយ ហើយដូច្នេះ pan-regionalismពេលការបង្រួបបង្រួមសាសនាឲ្យមានការឯកភាពតែមួយ វាផ្ទុយទៅនឹង pan-Arabism ឬ pan-Islamism ត្រូវបានលើកកម្ពស់ដោយអឺរ៉ុប និងសហរដ្ឋអាមេរិក ពេលដោយពួកគេមិនចង់ឃើញអ៊ីស្លាមរួបរួមគ្នាបាននោះឡើយ។ នៅក្នុងចក្ខុវិស័យនេះ មជ្ឈិមបូព៌ាទាំងមូល រួមទាំងអ៊ីស្រាអែល អាចត្រូវបានដាក់បញ្ចូលទៅក្នុងពិភពសកលភាវូបនីយកម្មរបស់មលោកខាងលិច។ ដូចនៅសម័យទំនើប Zionism ចលនាជ្វីហ្វនិយមជឿលើទំនាក់ទំនងដាច់ខាត ដូច្នេះវាបដិសេធនូវសញ្ញាណនៃសិទ្ធិ និងការពិត។ វាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលអំពើហិង្សាក្លាយជាចំណុចក្តៅកើតមានជាក់ស្តែងបំផុតដែលសម្រេចសម្រួចទៅកើតឡើង នូវការតស៊ូប្រឆាំងទៅវិញពីសំណាក់ជាតិសាសន៍អារ៉ាប់។[17]

Zionism ចលនាជ្វីហ្វនិយម គឺមិនមានករណីលើកលែងពីផែនទីនៃចក្រពត្តិនិយមនោះឡើយ ពីព្រោះសកម្មភាពរបស់ Zionist ត្រូវបានកំណត់យ៉ាងទូលំទូលាយដោយផែនទីការយល់ដឹងរបស់ Zionis ដែលផ្អែកលើអំណាច ទេវកថា ក្តីសង្ឃឹម ការភ័យខ្លាច និងការសន្យា ជាជាងការឆ្លើយតបដោយផ្ទាល់ទៅនឹងការពិតដ៏ស្មុគស្មាញនិ ងភាពផ្ទុយគ្នាដែលនៅជុំវិញវា។ Elmessiri តែងតែជជែកវែកញែកថា អ៊ីស្រាអែលមិនមែនជារដ្ឋជ្វីហ្វទេ ប៉ុន្តែជារដ្ឋអាណានិគមដែលតាំងទីលំនៅ ដែលបម្រើគោលបំណងជាក់ស្តែង និងមុខងារសំខាន់ពីរគឺ កម្ចាត់ភាពជាជនជាតិអឺរ៉ុបដែលជាតិជ្វីហ្វបានរស់នៅតកូនតចៅ និងដើរតួជារដ្ឋមានមុខងារដើម្បីបម្រើផលប្រយោជន៍របស់ចក្រពត្តិនិយមកខាងលិច។[18]

Elmessiri ប្រើគំរូនៃ "ក្រុមមុខងារ" ដើម្បីសំដៅទៅលើសហគមន៍ជ្វីហ្វ និងពាក្យ "ស្ថានភាពមុខងារ" ដើម្បីសំដៅទៅលើអ៊ីស្រាអែល។ ក្រោយមកទៀតគឺគ្មានអ្វីក្រៅពីរដ្ឋមុខងារបម្រើផលប្រយោជន៍របស់លោកខាងលិចនៅមជ្ឈិមបូព៌ា។ Bauman ខ្លួនគាត់ផ្ទាល់សំដៅទៅលើតួនាទីរបស់សហរដ្ឋអាមេរិចក្នុងការធានា "ការរស់រានមានជីវិតរបស់ប្រទេសពីអ៊ីស្រាអែលដូចទៅនឹងប្រទេសកូរ៉េខាងត្បូង"។[19]

នៅក្នុងបរិបទនេះ Elmessiri កំណត់និយមន័យនៅសម័យទំនើបថាជាមនោគមវិជ្ជានៃការទទួលយកជាក់ស្តែង ការចុះចាញ់ និងការសម្របខ្លួនរបស់អ្នកទន់ខ្សោយទៅនឹងស្ថានភាពបច្ចុប្បន្ន។ វាគឺជាការល្បែងលេងដោយឥតគិតថ្លៃ និងគ្មានដែនកំណត់ជាមួយនឹងការពិត ជំនួសឱ្យការដោះស្រាយឲ្យបានខ្លាំងក្លាជាមួយនឹងភាពផ្ទុយគ្នារបស់វានិងការផ្លាស់ប្តូរវា។[20]

# អ្នកនិពន្ធ

HAGGAG ALI បានសិក្សានៅសាកលវិទ្យាល័យគៃរ៍ ហើយបានទទួលសញ្ញាបត្របណ្ឌិតរបស់គាត់នៅក្នុងជំនាញនៃទ្រឹស្តីប្រៀបធៀបវប្បធម៌។ លោកបណ្ឌិត Ali បានសិក្សា និងទទួលបានអាហារូបករណ៍ជាច្រើននៅឯសាកលវិទ្យាល័យ Humboldt នៃទីក្រុង Berlin និង Wissenschaftskolleg zu Berlin។ គាត់ក៏ទទួលបានអាហារូបករណ៍ Georges-Anaawati ដ៏ល្បីល្បាញសម្រាប់គម្រោងស្រាវជ្រាវស្តីពីកិច្ចសន្ទនារវាងសាសនាអ៊ីស្លាម និងគ្រិស្តសាសនា។ ចំណាប់អារម្មណ៍នៃការស្រាវជ្រាវចម្បងរបស់បណ្ឌិតAli គឺការរិះគន់បែបអច្ឆរិយៈ និងការរិះគន់សហសម័យអំពីភាពទំនើប និងបច្ចុប្បន្នគាត់គឺជាអ្នកដឹកនាំក្រុមស្រាវជ្រាវនៅមជ្ឈមណ្ឌលសម្រាប់ការសិក្សាអរិយធម៌ និងការសន្ទនានៃវប្បធម៌នៅសាកលវិទ្យាល័យទីក្រុងគៃរ៍ ។ គម្រោងស្រាវជ្រាវរបស់គាត់ "Dissidence and Censorship in Modern Egypt" ត្រូវបានអនុវត្តក្នុងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ Bonn និងផ្តល់មូលនិធិដោយ DAAD (The German Academic Exchange Service) នៅក្នុងភាពជាដៃគូផ្លាស់ប្តូរគ្នារវាងអាល្លឺម៉ង់-អារ៉ាប់។

# កំណត់សម្គាល់

## ជំពូកទី១: ការណែនាំ

1 Elmessiri, *Riḥlaty al-Fikriyyah*, [My Intellectual Journey], (Cairo: Dār al-Shurūq, 2005), p.376.
2 Zubaida, "Trajectories of Political Islam," *Political Quarterly*, 2000, Supplement 1, vol.71, p.61.
3 Elmessiri, *Dirāsāt Maʿrifiyyah,* [Epistemological Studies in Western Modernity], (Cairo: Dār al-Shurūq International, 2006), pp.69-70.
4 Elmessiri, *Al- ʿAlmāniyyah al-Juzʿiyyah wa al-ʿAlmāniyyah al-Shāmilah,* [Partial Secularism and Comprehensive Secularism], (Cairo: Dār al-Shurūq, 2002), vol.1, pp.101-126.
5 Elmessiri, *Dirāsāt Maʿrifiyyah*, p.34.
6 Elmessiri, "Secularism, Immanence and Deconstruction," in *Islam and Secularism in the Middle East*. Ed. John Esposito and Azzam Tamimi. (London: Hurst & Co, 2000), p.68.
7 Elmessiri, *Al-Ṣuhyūniyyah wa al-Nāziyyah wa Nihāyat al-Tārīkh,* [Zionism, Nazism and the End of History] (Cairo: Dār al-Shurūq, 2001), p.299.
8 Elmessiri, *Riḥlaty al-Fikriyyah*, p.318.
9 Elmessiri, *Riḥlaty al-Fikriyyah*, p.543.
10 Achcar, *The Arabs and the Holocaust*. G.M. Goshgarian (trans.). (London: Saqi, 2011), p.20.
11 Bunting, "Passion and Pessimism," *Guardian*, London, 5 April, 2003, p.20.
12 Bauman and Vecchi, *Identity* (Cambridge: Polity Press, 2004), p.11.
13 Bauman, *Intimations of Postmodernity*, (London; New York: Routledge, 1992), p.28.
14 Bauman, *Postmodernity and its Discontents* (New York: New York University Press, 1997), p.97.
15 Shapira, "Life in a Liquid World," *Haaretz Daily Newspaper*, 16 November 2007.
16 Bauman, *Intimations of Postmodernity*, pp. 226-227.
17 Bauman, *Modernity and Ambivalence* (Ithaca, N.Y.: Cornell University Press, 1991), pp.129-140.
18 Bauman, "Assimilation into Exile," *Poetics Today*, vol.17, no. 4, 1996, pp.571-581.
19 Bauman, *Modernity and Ambivalence*, pp.129-140.

## ជំពូកទី២: វ៉ាឌីកាល់នៃការត្រាស់ដឹង

1 Bauman, *Modernity and the Holocaust* (Cambridge: Polity Press, 1989), p.92.
2 Bauman, *Postmodernity and its Discontents*, p.174.
3 Bauman, *Modernity and Ambivalence*, p.24.
4 Bauman, *Socialism: The Active Utopia* (New York: Holmes & Meier, 1976), p.24.
5 Kilminster & Ian Varcoe. "Addendum: Culture and Power in the Writings of Zygmunt Bauman," in *Culture, Modernity and Revolution: Essays in Honour of Zygmunt Bauman* (London: Routledge, 1996), p.217.
6 Bauman, *Towards a Critical Sociology*, pp.70-74.

[7] Bauman, *Modernity and Ambivalence*, p.71.
[8] Bauman, *Legislators and Interpreters* (Cambridge, UK: Polity Press, 1987), p.80.
[9] Torevell, "The Terrorism of Reason in the Thought of Zygmunt Bauman" (The Dominican Council/Blackwell Publishing Ltd), *New Blackfriars*, 1995, vol.76. Issue 891, p.145.
[10] Elmessiri, *Al-ʿAlmāniyyah al-Juzʿiyyah wa al- ʿAlmāniyyah al-Shāmilah*, vol.1, p.290.
[11] Elmessiri, *Al-ʿAlmāniyyah al-Juzʿiyyah wa al- ʿAlmāniyyah al-Shāmilah*, vol.1, pp.294-297.
[12] Wellman, *La Mettrie: Medicine, Philosophy, and Enlightenment* (Durham, NC.: Duke University Press, 1992), p.264.
[13] Bernstein, *The New Constellation* (Cambridge: Polity Press, 1991), p.40.

## ជំពូកទី៣: ទំនើបកម្មប្រៀបដូចជានិទានកថា

[1] Badawi, *Mawsūʿat al-Falsafah*, [Encyclopedia of Philosophy], (Beirut: al-Muʿassasah al-ʿArabiyyah li al-Dirāsāt wa al-Nashr, 1984), p.86.
[2] Bauman, *Life in Fragments* (Oxford UK and Cambridge USA: Blackwell, 1995), pp.15-16.
[3] Bauman, *Postmodernity and its Discontents* (New York: New York University Press), 1997, p.201.
[4] Elmessiri, "Secularism, Immanence and Deconstruction," p.75.
[5] Elmessiri, *Al-Lughah wa al-Majāz: Bayna al-Tawḥīd wa Wiḥdat al-Wujūd* [Language and Metaphor: between Monotheism and Pantheism], (Cairo: Dār al-Shurūq, 2002), p.56.
[6] Voegelin, *Science, Politics and Gnosticism*, Ellis Sandoz. Ed. (Washington, D.C.: Regnery Publishing, 1997), pp.68-69.
[7] Elmessiri, "Secularism, Immanence and Deconstruction," p.62.
[8] Elmessiri, *Al-ʿAlmāniyyah al-Juzʿiyyah wa al-ʿAlmāniyyah al-Shāmilah*, vol.1, p.149.
[9] Bauman, *Modernity and the Holocaust*, pp.67-68.
[10] Ibid., p.7.
[11] Bauman, Janina, "Demons of other People's Fear: The Plight of the Gypsies," *Thesis Eleven*, 1998, vol.54, No.1, pp.51-56.

## ជំពូកទី៤:ការធ្វើផែនទីពីផលវិបាកនៃភាពទំនើប

[1] Bauman, "The Fate of Humanity in a Post-trinitarian World," *Journal of Human Rights*, vol.1 (3), 2002, pp.283-303.
[2] Bauman, *Legislators and Interpreters*, pp.115-116.
[3] Bauman, *Modernity and the Holocaust*, pp.1-2.
[4] Ibid., p.31.
[5] Ibid., p.66.
[6] Ibid., p.13.
[7] Ibid., pp.14-18.
[8] Ibid., pp.71-72.
[9] Ibid., p.126.
[10] Ibid., p.108.
[11] Bauman, "Sociology after the Holocaust," *British Journal of Sociology*, 1988, vol.39, no. 4, pp.478-481.
[12] Elmessiri, *Riḥlaty al-Fikriyyah*, p.590.

[13] Bauman, *Modernity and the Holocaust*, p.61.
[14] Elmessiri, *The Land of Promise* (New Brunswick, N. J: North American, 1977), pp.44-45.

## ជំពូកទី៥: Bauman និងវិបត្តិនៅសម័យទំនើប

[1] Bauman, *Intimations of Postmodernity*, p.187.
[2] Bauman, *Liquid Life* (Cambridge; Malden, MA: Polity, 2005), p.2.
[3] Ibid., p.68.
[4] Bauman, *Intimations of Postmodernity*, p.50.
[5] Bauman, *Postmodernity and its Discontents*, p.2.
[6] Bauman, *Freedom* (Minneapolis: University of Minnesota Press, 1988), p.65.
[7] Bauman, "As Seen on TV," 2000a, *Ethical Perspectives*, vol.7 (2), pp.107-121.
[8] Bauman, *Postmodernity and its Discontents*, p.40.
[9] Bauman, "On Postmodern Uses of Sex," *Theory, Culture & Society* (London: Sage, 1998), vol.15 (3-4).
[10] Bauman, *Postmodernity and its Discontents*, p.149.
[11] Bauman, *Postmodernity and its Discontents*, p.93.

## ជំពូកទី៦: Elmessiri និងសម័យទំនើបដែលប្រៀបដូចជាអង្គធាតុរាវ

[1] Elmessiri, *Al-Ḥadāthah wa mā Baʿda al-Ḥadāthah* (Damascus: Dār al- Fikr, 2003), pp.83-86.
[2] Elmessiri, *Al-ʿAlmāniyyah al-Juzʿiyyah wa al-ʿAlmāniyyah al-Shāmilah*, vol.2, pp.286-293.
[3] Elmessiri, *Al-Lughah wa al-Majāz*, p.73.
[4] Elmessiri, *Riḥlaty al-Fikriyyah*, p.248.
[5] Elmessiri, *Al-Lughah wa al-Majāz*, p.47.
[6] Elmessiri, *Dirāsāt Mʿarifiyyah*, pp.256-260.
[7] Elmessiri, *Al-ʿAlmāniyyah al-Juzʿiyyah wa al-ʿAlmāniyyah al-Shāmilah*, vol.2, pp.160-168.
[8] Elmessiri, *Riḥlaty al-Fikriyyah*, p.246.
[9] Elmessiri, "The Imperialist Epistemological Vision," *The American Journal of Islamic Social Sciences* (AJISS), Washington, DC and Kuala Lumpur, Malaysia, vol.11. no.3, 1994, p.413.
[10] Elmessiri, *Al-ʿAlmāniyyah al-Juzʿiyyah wa al-ʿAlmāniyyah al-Shāmilah*, vol.1, p.108.
[11] Elmessiri, *Al-Lughah wa al-Majāz*, pp.74-88.
[12] Elmessiri, *Riḥlaty al-Fikriyyah*, p.249.
[13] Silverman, *Facing Postmodernity* (London and New York: Routledge, 1999), p.23.
[14] Elmessiri, *Al-Ḥadāthah wa mā Baʿda al-Ḥadāthah*, pp.140-143.
[15] Elmessiri, "Understanding the Holocaust," 2000b, *Al-Ahram Weekly*, No.507.
[16] Elmessiri, "The Imperialist Epistemological Vision," p.415.
[17] Elmessiri, *Al-Ḥadāthah wa mā Baʿda al-Ḥadāthah*, p.155.
[18] Elmessiri, "The Cognitive Map," 2008, *Al-Ahram Weekly*, No.878.
[19] Bauman, *Europe: An Unfinished Adventure* (Cambridge: Polity, 2004), p.48.
[20] Elmessiri, *Al-Ḥadāthah wa mā Baʿda al-Ḥadāthah*, p.93.

IIIT Books-In-Brief Series គឺជាការប្រមូលដ៏មានតម្លៃលើការបោះពុម្ពផ្សាយដែលសំខាន់ៗរបស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ រៀបរៀងជាទម្រង់បង្រួម ផ្តល់ឱ្យអ្នកអាននូវការយល់ដឹងអំពីខ្លឹមសារសំខាន់ៗនៃសៀវភៅច្បាប់ដើម។

**ការធ្វើផែនទីចិត្តនៃលោកិយនិយម** ពិនិត្យមើលបញ្ហានៃហេតុផលសនិទានភាព និងសម្ភារៈនិយមខាងលោកិយ ដើម្បីស្វែងយល់ពីរបៀបផ្លូវចិត្តទាំងនេះការយល់ឃើញ ឬវិធីនៃការគូសផែនទីពិភពលោក បានជះឥទ្ធិពលដល់អន្តរកម្មរបស់មនុស្ស និងការអភិវឌ្ឍសង្គមវិទ្យា។ ការធ្វើបែបនេះជាការប្រៀបធៀប និងផ្ទុយពីគំនិតរបស់ Abdelwahab M. Elmessiri (1938–2008) ដែលជាបញ្ញវន្តអារ៉ាប់ឈានមុខគេ និង Zygmunt Bauman (1925) ដែលជាអ្នកសង្គមវិទូឈានមុខគេរបស់ពិភពលោក។នៅ ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការរិះគន់លោកខាងលិចដែលកំពុងលេចចេញអំពីភាពទំនើបបានបំផុសគំនិតបញ្ញវន្តមូស្លីមឱ្យបង្កើតគំនិតថ្មី រូបភាពលក្ខខណ្ឌ និងគោលគំនិតដែលបង្ហាញពីជំហររបស់ពួកគេចំពោះទំនោរនៃភាពទំនើបខាងលោកិយ ការផ្លាស់ប្តូរ និងផលវិបាករបស់វា និងរបៀបដែលវាគ្រប់គ្រងការយល់ឃើញពីការពិត។

ចិត្តនៃលោកិយនិយមមានផែនការធំមួយដើម្បីបង្កើតឋានសួគ៌លើផែនដី សង្គមទីនេះ និងបច្ចុប្បន្ននេះ អរិយធម៌ទំនើបដែលគ្រប់គ្រងដោយហេតុផលរបស់មនុស្សសនិទានភាព និងជ័យជំនះនៃវឌ្ឍនភាព។ ខណៈពេលដែលឧត្តមគតិគឺជារឿងមួយ វាជាមធ្យោបាយដើម្បីដឹងថាវាជាអ្វីផ្សេងទៀត។ ឆ្ងាយពីការឃោសនាបំផ្លើស ការរំដោះមនុស្សចេញពី 'ខ្សែពួរ' នៃជំនឿលើព្រះ និងសាសនា មិនមែនជារឿងងាយស្រួលនោះឡើយ។

979-8-89193-329-3
9 798891 933293

Cambodia Office
IIIT Books-in-Brief